ដេប៉ាតឺម៉ង់ស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី

NEW GENERATION PEDAGOGICAL RESEARCH DEPARTMENT

# ការរៀបចំកិច្ចតែងការបង្រៀន




**Stanislas Kowalski**

**Pilot Edition: 2026**

# ដេប៉ាតឺម៉ង់ស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី

New Generation Pedagogical Research Department

សៀវភៅ៖

# ការរៀបចំកិច្ចតែងការបង្រៀន

២០២៦

សៀវភៅស្តីពីការរៀបចំកិច្ចតែងការបង្រៀននេះត្រូវបានចែករំលែកក្រោមអាជ្ញាប័ណ្ណ គ្រីអេធីវ ខំាមិនស៍ (Creative Commons) សម្រាប់កំណែអេឡិចត្រូនិចជាភាសាខ្មែរ។

CC BY-NC-ND 4.0

Attribution-NonCommercial-NoDerivatives 4.0 International

អាជ្ញាប័ណ្ណនេះអនុញ្ញាតឱ្យអ្នកប្រើប្រាស់បន្តចម្លង និងចែកចាយឯកសារគ្រប់ទម្រង់ ឬ មធ្យោបាយណាមួយ *ក្នុងទម្រង់ដែលគ្មានការកែប្រែតែប៉ុណ្ណោះ* សម្រាប់ *គោលបំណងមិនមែនពាណិជ្ជកម្ម* និង *លុះត្រាតែមានការផ្តល់ក្រេឌីត ដល់ស្ថាបនិក*។

**តាមរយៈ** CC BY-NC-ND រួមបញ្ចូលធាតុដូចខាងក្រោម៖

BY (ការផ្តល់ក្រេឌីត)៖ **សៀវភៅនេះនិពន្ធដោយលោក Stanislas Kowalski ដោយមានជំនួយបកប្រែដោយលោក ភេ សៅរិទ្ធ** និងជាមួយដេប៉ាតឺម៉ង់ស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី (NGPRD) ។

NC (មិនមែនពាណិជ្ជកម្ម)៖ អនុញ្ញាតឱ្យប្រើប្រាស់ស្នាដៃនេះសម្រាប់តែ *គោលបំណងមិនមែនពាណិជ្ជកម្ម* ប៉ុណ្ណោះ។

ND (មិនមានការការប្រែ ឬសម្រួលលើស្នាដៃដើម)៖ *មិនអនុញ្ញាត* ឱ្យមានការបង្កើតស្នាដៃកែច្នៃ ឬសម្របសម្រួលលើខ្លឹមសារណាមួយនៃស្នាដៃដើមឡើយ។

**ដើម្បីសុំសិទ្ធិក្នុងការបកប្រែ សូមទាក់ទងមកដេប៉ាតឺម៉ង់ស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី** (NGPRD) **តាមរយៈ** ngprc.faculty@gmail.com

**មាតិកា** **ទំព័រ**

សេចក្តីផ្តើម ........................................ 1
ភាពជាក់លាក់ផ្សេងៗសម្រាប់កិច្ចតែងការបង្រៀនល្អ .................... 2
អាចប្រើបានក្នុងស្ថានភាពអាសន្ន .................... 4
ទុកជាឯកសារយោង .................... 5
ការប៉ាន់ស្មានពេលវេលា .................... 7
ការកំណត់ពេលវេលា .................... 7
ប្រើកម្មវិធីកំណត់ម៉ោងឬអត់ ? .................... 8
សកម្មភាពបណ្តោះអាសន្ន .................... 8
ការសរសេរវត្ថុបំណងមេរៀន .................... 9
វត្ថុបំណងដែលអាចសង្កេតបាន .................... 12
ពន្យល់ពីវត្ថុបំណងមេរៀនទៅកាន់សិស្ស .................... 14
ប្លូមតាក់សូណូមី .................... 15
ការសរសេរវត្ថុបំណងមេរៀនតាមគំរូ KSA .................... 18
ការរចនាសកម្មភាព .................... 20
ខ្លឹមសារមេរៀន .................... 20

ដំណើរការ ........................................................................ 21
លទ្ធផល ........................................................................ 24
ការប្រើបញ្ញាសិប្បនិម្មិតដើម្បីរចនាកិច្ចតែងការបង្រៀន ............... 25
គំរូទី ១ ........................................................................ 38
គំរូទី ២ ........................................................................ 41
គំរូទី ៣ ........................................................................ 45

## សេចក្តីផ្តើម៖

## ហេតុអ្វីបានជាត្រូវរវល់ជាមួយការធ្វើកិច្ចតែងការបង្រៀន?

ជាតម្រូវការរដ្ឋបាល ឬឧបករណ៍ដែលត្រូវប្រើក្នុងស្ថានភាពជាក់ស្តែង។ ប្រព័ន្ធសាលារៀនឬអ្នកគ្រប់គ្រងជាច្រើន តម្រូវឱ្យគ្រូបង្រៀនសរសេរកិច្ចតែងការបង្រៀន។ កាតព្វកិច្ចរដ្ឋបាលនេះច្រើនតែប្រែក្លាយទៅជារឿងដែលមិនសមហេតុសមផល។ ខ្ញុំបានជួបសម្ភាសជាមួយគ្រូច្រើននាក់ដែលបានសរសេរកិច្ចតែងការបន្ទាប់ពីការបង្រៀនមេរៀនរួច។ ពួកគេបានខ្ជះខ្ជាយពេលវេលារបស់ខ្លួនក្នុងការសរសេរ ហើយជាពិសេសនោះគឺពួកគេរៀបចំសកម្មភាពខុសពីការពិតនៃការបង្រៀនមេរៀនជាក់ស្តែង។ ប្រសិនបើអ្នកធ្វើកិច្ចតែងការបង្រៀនវាគួរតែត្រូវបានប្រើសម្រាប់ហេតុផលដ៏ត្រឹមត្រូវ។ ហេតុផលជាមូលដ្ឋាននោះគឺត្រូវដឹងពីអ្វីដែលអ្នកចង់បាននិងចងចាំវាក្នុងចិតគ្រប់ពេល។ លើសពីនេះ កិច្ចតែងការបង្រៀនមានប្រយោជន៍ព្រោះកិច្ចតែងការមានគោលបំណងដូចខាងក្រោម៖

- ❖ សម្រាប់ជំនួសអ្វីមួយ។ ការសរសេរកិច្ចតែងការបង្រៀនបានទៀងទាត់ជាការកត់ត្រាការងាររបស់អ្នក និងផ្តល់ឱ្យគ្រូជំនួស ដឹងច្បាស់ពីអ្វីដែលបានធ្វើកន្លងមក។ ជាវិធីដ៏ល្អមួយក្នុងការផ្តល់ការណែនាំដល់គ្រូជំនួសនិងជួយ សម្រួលដល់ការត្រឡប់ទៅបង្រៀនក្នុងថ្នាក់រៀនរបស់អ្នកវិញ។

- ឆ្លើយតបក្នុងករណីមានបញ្ហា។ ជាមួយនឹងកិច្ចតែងការបង្រៀនដ៏ល្អ អ្នកអាចត្រៀមខ្លួនសម្រាប់ ឧប្បត្តិហេតុផ្សេងៗដែល អាចកើតក្នុងអំឡុងពេលបង្រៀន។
- ប្រើជាមតិត្រឡប់។កិច្ចតែងការបង្រៀនកត់ត្រានូវអ្វីដែលអ្នកបានធ្វើ និង ផ្តល់ឱ្យអ្នកកត់ត្រា មតិត្រឡប់ចំពោះសកម្មភាពដែលបានធ្វើ ហើយដើម្បីយកវាមកប្រើម្តងទៀតសម្រាប់ថ្នាក់បង្រៀនផ្សេងទៀត ។ កិច្ចតែងការបង្រៀនរបស់អ្នកគឺជាជំហានដំបូងដើម្បីបង្កើតបណ្ណសារដែលមានប្រយោជន៍ និងអាចកាត់បន្ថយបន្ទុកការងាររបស់អ្នកនាពេលខាងមុខ។ ដូច្នេះសូមចាត់ទុកកិច្ចតែងការបង្រៀនរបស់អ្នកជាការវិនិយោគពេលវេលាដ៏ល្អរបស់ខ្លួន។

## ភាពជាក់លាក់ផ្សេងៗសម្រាប់កិច្ចតែងការបង្រៀនល្អ។ សម្រាប់ផ្ទាល់ខ្លួន

កិច្ចតែងការបង្រៀនគឺជាឯកសារផ្ទាល់ខ្លួន។ គ្មានប្រយោជន៍អ្វីទេកាលដែលចម្លងកិច្ចតែងដែលសរសេរដោយអ្នកដ៏ទៃ។ អ្នកមានសៀវភៅសិក្សាគោលក្នុងដៃរួចទៅហើយ ហើយបន្ថែមពីនោះទៀតអ្នកក៏មានសៀវភៅណែនាំគ្រូផងដែរ។ ប៉ុន្តែរឿងដែលចាំបាច់នោះគឺជាការសរសេរនូវការសម្រេចចិត្តផ្ទាល់ខ្លួនរបស់អ្នកអំពីមេរៀនដែលនឹងត្រូវបង្រៀននៅថ្ងៃបន្ទាប់។ អ្នកនឹងឃើញគំរូមួយចំនួននៅក្នុងឧបសម្ព័ន្ធ ប៉ុន្តែរឿងដែលសំខាន់បំផុតដែលត្រូវពិចារណានោះគឺអ្នកត្រូវតែសាំជាមួយនឹងវា។ ដូច្នេះយើងសូមណែនាំឱ្យអ្នកយកវាទៅប្រើឱ្យស្របតាមតម្រូវការរបស់អ្នក។ ជាធម្មតាគ្រូផ្សេងគ្នាមានទំនោរ

ភ្លេចរឿងផ្សេងគ្នា និងមានចំណុចខ្លាំងខុសៗគ្នា។ ដើម្បីជ្រើសរើសលក្ខណៈពិសេសណាមួយដែលត្រូវយកចិត្តទុកដាក់ សូមពិចារណាពីអ្វីដែលអ្នកធ្វើមិនល្អជារៀងរាល់ថ្ងៃ។ ប្រសិនបើអ្នកមានទំនោរប្រើវាក្យសព្ទមិនច្បាស់ សូមសរសេរនិយមន័យដែលអ្នកចង់ឱ្យសិស្សចងចាំ។ ប្រសិនបើអ្នកមានទំនោរភ្លេចកិច្ចការស្រាវជ្រាវដែលអ្នកផ្តល់ឱ្យសិស្ស សូមរៀបចំកិច្ចតែងការដោយពិនិត្យមើលកិច្ចការនៅដើមនៃមេរៀន។ ប្រសិនបើអ្នកមានភាពច្បាស់លាស់ជាមួយនឹងខ្លឹមសារមេរៀនដែលបង្រៀន ប៉ុន្តែអ្នកមានអារម្មណ៍ថាការណែនាំសកម្មភាពមានភាពស្មុគស្មាញ សូមពណ៌នាអំពីដំណើរការនៃសកម្មភាពដោយប្រុងប្រយ័ត្ន (ដូចជាការរៀបចំក្រុមសន្លឹកកិច្ចការពេលវេលា) ប៉ុន្តែអ្នកមិនចាំបាច់សរសេរចម្លើយលំហាត់ទាំងអស់នោះទេ។ កម្រិតលម្អិតមេរៀនអាស្រ័យលើគ្រូម្នាក់ៗ។ នៅចុងបញ្ចប់នៃសកម្មភាពនីមួយៗ វាអាចជាការកំណត់ចំណាំសាមញ្ញៗដែលមាន បួន ឬប្រាំឃ្លាដូចជា៖

| |
|---|
| វិធីសម្តែងតួលើប្រធានបទ៖ «ប្តីមកដល់ផ្ទះយឺតពេក នាំឱ្យប្រពន្ធខឹង»។ ចូរប្រើវាក្យសព្ទនៃការស្តីបន្ទោសប្រើជាមួយពាក្យ"គួរ" ឬ"មិនគួរ"។ កុំភ្លេចចោទជាសំណួរសួរតាព។ |

ជាក់ស្តែង ភាពលម្អិតមិនត្រូវបានផ្តល់យោបល់ឱ្យអ្នកក្នុងការសង្ខេបខ្លឹមសារមេរៀននោះទេ តែគួរតែត្រូវធ្វើក្នុងករណីមានការចុះអធិការកិច្ច ឬក្នុងករណីដែលអ្នកត្រូវបានជំនួសដោយគ្រូម្នាក់ទៀត។ ប៉ុន្តែវាអាចធ្វើទៅបានយ៉ាងល្អឥតខ្ចោះក្នុងការបង្រៀនមេរៀនដោយជោគជ័យ ប្រសិនបើដំណើរការនៃការសម្តែងតួត្រូវបានបង្កើតជាទម្លាប់ដែលបានកំណត់រួចហើយ ប្រសិនបើវាក្យ

សព្វត្រូវបានរៀនក្នុងមេរៀនមុន ហើយប្រសិនបើគ្រូជាអ្នកនិយាយភាសាដើមកំណើត នោះអាចកែកំហុសរបស់សិស្សបានភ្លាមៗ។

លើសពីនេះផ្នែកខាងលើនៃកិច្ចតែងការបង្រៀនអាចជាការរៀបចំរយៈពេលនៃជំហានក្នុងការធ្វើសន្លឹកកិច្ចការ បូករួមទាំងសកម្មភាពបន្ថែម និងការរំលឹកក្នុងករណីមានបញ្ហា ឬសំណួរពិបាក។

## អាចប្រើបានក្នុងស្ថានភាពអាសន្ន

ថ្នាក់រៀនអាចមានភាពមមាញឹក។ សិស្សខ្លះសួរសំណួរដែលមិននឹកស្មានដល់ ខ្លះជជែកគ្នា ប្រហែលជាការ ទាស់ទែងអាចនឹងកើតឡើង។ អ្នកណាដឹង? ឧប្បត្តិហេតុកើតឡើង។ គ្រូខិតខំអស់ពីសមត្ថភាពដើម្បីបញ្ចៀសបញ្ហាទាំងនេះ ប៉ុន្តែវាមិនតែងតែអាចធ្វើទៅបានដោយរលូននោះទេ សូម្បីតែពួកយើងមានសមត្ថភាពយ៉ាងណាក៏ដោយ។ អ្វីដែលសំខាន់គឺត្រូវត្រៀមខ្លួនជាស្រេចដើម្បីដោះស្រាយឧបទ្ទវហេតុ និងអាចបន្តមេរៀនបានលឿនតាមដែលអាចធ្វើទៅបាន។

ការរៀបចំកិច្ចតែងការបង្រៀនបានត្រឹមត្រូវនឹងជួយអ្នកនូវរឿងពីរនោះគឺ៖ កាត់បន្ថយឧទ្ទវហេតុ និងការបន្ត មេរៀនឡើងវិញ។ ប៉ុន្តឧបទ្ទវហេតុគួរត្រូវបានគិតមុន។ ដាក់កិច្ចតែងការបង្រៀនរបស់អ្នកនៅលើតុហើយក្រោកឈរឡើង។ អ្នកគួរតែអាចអានវាដោយមិនចាំបាច់បត់។ អ្នកគួរតែអាចទាញយកសកម្មភាពឬលំហាត់បន្ទាប់ក្នុងរយៈពេលប៉ុន្មានវិនាទីដោយមិនគិតពីអ្វីដែលទើបតែកើតឡើង។

ខាងក្រោមនេះជាការណែនាំមួយចំនួនសម្រាប់ប្លង់នៃកិច្ចតែងការបង្រៀន៖

- សរសេរវាឱ្យសាមញ្ញ។
- ប្រើប្រភេទអក្សរ និងទំហំអក្សរតូច ហើយមានគោលបំណងច្បាស់លាស់។
- គិតពីសកម្មភាពដែលជាអាទិភាព។
- សង្កត់ធ្ងន់លើអ្វីដែលសំខាន់ ហើយកាត់បន្ថយអ្វីដែលមិនសូវសំខាន់ចេញ។
- ប្រើរូបភាព និងពណ៌ ប៉ុន្តែកុំធ្វើឱ្យវារញ៉េរញ៉ៃ។

## ទុកជាឯកសារយោង

ចូរកុំខ្ជះខ្ជាយកិច្ចខិតខំប្រឹងប្រែងដែលអ្នកបានធ្វើនៅពេលបង្កើតកិច្ចតែងការបង្រៀន។ ទុកវាសម្រាប់ប្រើពេលក្រោយ។ រក្សាបណ្ណសារត្រឹមត្រូវ។ នោះហើយជាអ្វីដែលនឹងធ្វើឱ្យអ្នកក្លាយជាគ្រូបង្រៀនដ៏មានប្រសិទ្ធភាពក្នុងរយៈពេលមួយហើយមិនមែនជាអ្នកដែលពឹងផ្អែកទាំងស្រុងលើទម្លាប់ដដែលរបស់ខ្លួននោះទេ។

ដាក់កាលបរិច្ឆេទនៅលើឯកសារទាំងអស់ ដើម្បីរកមើលភាពហួសសម័យនៃមេរៀនរបស់អ្នក។ ត្រូវប្រាកដថាកិច្ចតែងការទាំងនោះនៅតែប្រើបានស្របតាមកម្មវិធីសិក្សា។ ការមានប្រព័ន្ធសរសេរកូដអាចមានប្រយោជន៍។

**ឧទាហរណ៍៖**

**មុខវិជ្ជា (គណិតវិទ្យា) ថ្នាក់ (ថ្នាក់ទី៨) មេរៀន (ត្រីកោណមាត្រ) ប្រធានបទ (កូស៊ីនុស) លំដាប់មេរៀន (មេរៀនទី១) ប្រភេទសកម្មភាព (ការសហការ)។**

អ្វីដែលអ្នកដាក់ក្នុងកូដយោងរបស់អ្នកគឺអាស្រ័យលើទម្លាប់ផ្ទាល់ខ្លួនរបស់អ្នក និងលើប្រធានបទដែលអ្នកបង្រៀន។ ព្យាយាមសរសេរវាឱ្យសាមញ្ញ និង មានភាពងាយស្រួល។ ដើម្បីប្រើកិច្ចតែងការបង្រៀនចាស់ឡើងវិញ សូម ពិនិត្យមើលមតិត្រឡប់ដែលអ្នកបានសរសេរទុក។ អានវាម្តងហើយម្តងទៀត ឱ្យបានច្រើនដង។ វាអាចជួប បញ្ហាកាលបើអ្នកសន្មតថា ខ្លួនអាចបង្រៀនមេរៀនម្តងទៀតបាន ដោយមិនចាំបាច់មើលឡើងវិញ ដើម្បីរំលឹកអ្វីដែលត្រូវបង្រៀន។
ភាពបរាជ័យជាច្រើនកើតចេញពីកំហុសនៃការធ្វេសប្រហែសនោះឯង។

## ការប៉ាន់ស្មានពេលវេលា

ការប៉ាន់ស្មានពេលវេលាគឺជារឿងដ៏លំបាកបំផុតនៃការធ្វើកិច្ចតែងការ។ ធ្វើលំហាត់ដោយខ្លួនឯង ដើម្បីប៉ាន់ស្មានពីពេលវេលាដែលត្រូវការ។ ការធ្វើបែបនេះក៏បានផ្តល់ឱ្យអ្នករកឃើញនូវកំហុសដែលអាចកើតមាន និងភាពមិនច្បាស់លាស់នៅក្នុងការណែនាំ។ អ្នកអាចសន្មតថា សិស្សនឹងត្រូវការពេលពីរ ឬបីដងច្រើនជាងពេលដែល អ្នកបានចំណាយពេលធ្វើវា។ ជាការពិតណាស់ តួលេខនៃរយៈពេលអាចប្រែប្រួលទៅតាមកម្រិតសមត្ថភាពរបស់សិស្ស និងទៅតាមភាពស្ទាត់ជំនាញរបស់អ្នកផ្ទាល់។

បន្ទាប់ពីបង្រៀនមេរៀនហើយវាពិតជាមានប្រយោជន៍ណាស់ក្នុងការសរសេរពេលវេលាជាក់ស្តែងដែលសិស្សបានចំណាយលើការបង្រៀនរបស់អ្នក។

ដូច្នេះអ្នកនឹងអាចធ្វើកិច្ចតែងការបង្រៀនបានកាន់តែល្អនៅពេលដែលអ្នកត្រូវបង្រៀនមេរៀននោះម្តងទៀត។

## ការកំណត់ពេលវេលា

សកម្មភាពដែលអ្នករៀបចំគួរតែមានពេលវេលាកំណត់។ ផ្តល់ការណែនាំដល់សិស្សថាពួកគេមានពេល 5 នាទី ឬ 10 ឬ 1 ម៉ោងដើម្បីធ្វើកិច្ចការហើយត្រូវផ្តោតជាមួយតែកិច្ចការនោះ។ ហ៊ានទទួលយកភាពខ្វះខាតលើសកម្មភាពបង្រៀនរបស់ខ្លួន។ ការទទួលស្គាល់នូវភាពខ្វះខាតរបស់ខ្លួន មានសារៈសំខាន់ជាពិសេសនៅពេលដែលសកម្មភាពទាមទារឱ្យមានការពិភាក្សាខ្លះៗ ឬមានភាពច្នៃប្រឌិត។ សិស្សនឹងតែងតែប្រើប្រាស់ពេលវេលាដែលបានបែងចែកមិនថារយៈពេលប៉ុន្មាននោះទេ។

រៀបចំការរំលឹក និងជំហានជំហានតភ្ជាប់ ប្រសិនបើចាំបាច់។ ប្រសិនបើសកម្មភាពប្រើរយៈពេលយូរជាងដប់នាទីនោះវាជាការល្អក្នុងការជូនព័ត៌មានដល់សិស្សពីពេលវេលាសំខាន់ៗនៅក្នុងដំណើរការ៖ "ឥឡូវនេះឈប់គិតអំពីប្រធានបទនោះតទៅទៀត ហើយចាប់ផ្តើមសរសេរ។" ការផ្តល់សញ្ញាបែបនេះពិតជាសំខាន់ សម្រាប់ការងារជាក្រុមលុះត្រាតែអ្នកបានបណ្តុះបណ្តាលក្រុមឱ្យចេះកំណត់ម៉ោងពេលកំពុងពិភាក្សា។ ជាធម្មតាអ្នកអាចលែលកពេលវេលាឱ្យតិចជាងពាក់កណ្តាលដើម្បីគិតអំពីខ្លឹមសារ រីឯពេលពាក់កណ្តាលទៀតត្រូវលែសម្រាប់ការសរសេរចម្លើយ ហើយពីរបីនាទីចុងក្រោយសម្រាប់ការពិនិត្យអក្ខរាវិរុទ្ធ។ ជាការពិតណាស់ រយៈពេលត្រូវបានរាប់ចាប់ពីនាទីដែលអ្នកបានបញ្ចប់ការពន្យល់របស់ខ្លួន។

## ប្រើកម្មវិធីកំណត់ម៉ោងឬអត់?

សិស្សកោតសរសើរចំពោះគ្រូបង្រៀនដែលដឹងពីអ្វីដែលពួកគេចង់បាន ហើយមិនបន្តមេរៀនរបស់ខ្លួនបន្ទាប់ពីម៉ោងបង្រៀនអស់។ ទោះយ៉ាងណាក៏ដោយសិស្សក៏មិនចូលចិត្តភាពតានតឹងនៃកម្មវិធីកំណត់ម៉ោងនោះដែរ។ អ្នកគួរតែប្រើវា លុះត្រាតែការគ្រប់គ្រងពេលវេលាមានការពិបាកចំពោះអ្នក។ ហើយអ្នកគួរតែកំណត់វាពីរបីនាទីមុនពេលបញ្ចប់មេរៀនជាក់ស្តែងរបស់ខ្លួន ដូច្នេះអ្នកអាចបញ្ចប់សកម្មភាពដោយរលូន។

## សកម្មភាពបណ្តោះអាសន្ន

វាមានភាពងាយស្រួលក្នុងការរៀបចំសកម្មភាពបណ្តោះអាសន្នមួយចំនួន ជាពិសេសប្រសិនបើអ្នកកំពុងធ្វើ លំហាត់ខ្លីៗ ដែលភាគច្រើនមិនអាច

ពង្រីកពេលវេលាយូរបាន។ តាមរយៈសកម្មភាពបណ្តោះអាសន្ន ខ្ញុំមានន័យថា សកម្មភាពដែលអាចត្រូវបានប្រើដើម្បីបំពេញចន្លោះ ពេលវេលាឱ្យមានផលិតភាព។ ទាំងនេះគឺជាសកម្មភាព សិក្សាដែលអ្នកអាចបោះបង់ចោលបាន ប្រសិនបើអ្នកអស់ពេល។ ល្បែងសិក្សាខ្លះជួយបំពេញចន្លោះនោះបាន ដោយអ្នកគ្រាន់តែជៀសវាងការប្រើសកម្មភាពដែលឥតប្រយោជន៍។

## ការសរសេរវត្ថុបំណងមេរៀន
## ការគិតពីគោលដៅ

ការធ្វើគម្រោងទាមទារឱ្យមាននូវចក្ខុវិស័យច្បាស់លាស់អំពីគោលដៅ។វាមិនមានបញ្ហាទេប្រសិនបើយើងកំពុងនិយាយអំពីការបង្រៀនការធ្វើដំណើរឬការសាងសង់។ ជាធម្មតា អ្នកនឹងរៀបចំផែនការបែបបញ្ច្រាសទិសនោះគឺចាប់ផ្តើមពីគោលដៅចុងក្រោយមកវិញដើម្បីពិចារណាពីជំហានផ្សេងៗ ដែលចាំបាច់ដើម្បីសម្រេចវាបាន។

ចំណេះដឹងដ៏ល្អអំពីចំណុចចាប់ផ្តើមក៏សំខាន់ដែរ ប៉ុន្តែជាទូទៅវាមានភាពងាយស្រួល និងប្រកបដោយ វិចារណញាណជាង។ ទោះជាយ៉ាងណាក៏ដោយប្រសិនបើអ្នកត្រូវបង្រៀនក្នុងថ្នាក់ថ្មី ឬប្រសិនបើមេរៀនមើលទៅពិបាកវាជាការសំខាន់ដែលត្រូវប្រើតេស្តខ្លីបែបវិនិច្ឆ័យពីភាពខ្លាំង និងខ្សោយរបស់សិស្ស។ ជាឧទាហរណ៍ប្រសិនបើអ្នកកំពុងបង្រៀនមេរៀនរូបវិទ្យានៅថ្នាក់ទី៧ ចូរពិនិត្យមើលថាតើសិស្សចងចាំពីឯកតារង្វាស់រង្វាល់ ដែលពួកគេ បានរៀននៅសាលាបឋមសិក្សាដែរឬទេ ដូចជាក្រាម, គីឡូក្រាម, ម៉ែត្រ, លីត្រ។ល។ ការអានកម្មវិធីសិក្សាដោយយកចិត្តទុកដាក់ គឺជាកត្តាចាំបាច់

ដើម្បីស្វែងយល់ពីគោលបំណងទូទៅនៃមុខវិជ្ជា។

មិនត្រឹមតែកម្មវិធីសិក្សានៃថ្នាក់របស់អ្នកដែលកំពុងបង្រៀនប៉ុណ្ណោះទេ ប៉ុន្តែត្រូវអានកម្មវិធីសិក្សាទាំងអស់នៃ មុខវិជ្ជារបស់អ្នករហូតដល់បញ្ចប់ថ្នាក់វិទ្យាល័យ។ វាអាចជារឿងសំខាន់ជាងអ្វីដែលអ្នកកំពុងគិត។ សិស្សចំនួនដ៏ច្រើនលើសលប់ បានបញ្ចប់ថ្នាក់ទី១២ ដោយគ្មានសមត្ថភាពក្នុងការទំនាក់ទំនង ឬមិនអាចអានសៀវភៅជា ភាសាអង់គ្លេសបាន ដោយសារគ្រូរបស់ពួកគេព្យាយាមពន្យល់តែមេរៀនសំខាន់ខ្លីៗហើយពួកគេក៏បានភ្លេចប្រើសកម្មភាពអនុវត្តសំខាន់ៗដែលនាំឱ្យសិស្សឆាប់យល់ពីខ្លឹមសារមេរៀនរបស់ខ្លួន។ វាពិតជាគួរឱ្យសោកស្តាយកាលដែលសង្កេតឃើញថា លោកគ្រូអ្នកគ្រូ បានខ្ជះខ្ជាយពេលវេលាអស់ជាច្រើនឆ្នាំ។

ជំហានបន្ទាប់ អ្នកអាចវិភាគវត្ថុបំណងនៃជំពូកមរៀននីមួយៗ ហើយស្វែងយល់ពីវត្ថុបំណងនីមួយៗដើម្បីឱ្យកាន់តែយល់ច្បាស់ពីគោលបំណងរួមទូទៅ។ ជាការពិត គ្រូបង្រៀនជាច្រើនអាចស្វែងរកវត្ថុបំណងក្នុងសៀវភៅសិក្សាគោល ឬក្នុងសៀវភៅណែនាំគ្រូ ប៉ុន្តែក្នុងករណីខ្លះ វត្ថុបំណងអាចទាញបានពីការយល់ដឹងច្បាស់លាស់ អំពីគោលបំណងរួមទូទៅនៃប្រធានបទនិងពីការវាយតម្លៃបែបវិនិច្ឆ័យផ្សេងៗ។ អ្នកក៏អាចពិចារណាបន្ថែមលើសៀវភៅសិក្សាគោលដែលមើលទៅខ្វះខាតលើចំណុចមួយចំនួន ជាពិសេសប្រសិនបើមានគម្លាតរវាងកម្រិតថ្នាក់បច្ចុប្បន្ន និងអ្វីដែលសិស្សត្រូវរៀន។ ប្រសិនបើសិស្សរបស់អ្នកមិនស្គាល់អក្ខរក្រមក្នុងភាសាអង់គ្លេសនៅថ្នាក់ទី៧ ទោះបីជាមេរៀនរបស់ពួកគេត្រូវរៀននៅសាលាបឋមសិក្សាក៏ដោយ កុំយកមេរៀនអំពីកិរិយាស័ព្ទប្រែប្រួលទៅបង្រៀន ហើយចាប់ផ្តើមគ្នួញត្អែរ។ ជំនួស

មកវិញអ្នកគ្រាន់តែបង្រៀនអក្ខរក្រមភាសាអង់គ្លេសដល់ពួកគេ ព្រោះវាជាទន់ដែលត្រូវការដើម្បីធ្វើសកម្មភាពអនុវត្តផ្សេងទៀត។

នៅពេលដែលអ្នកមានចក្ខុវិស័យច្បាស់លាស់អំពីអ្វីដែលអ្នកចង់បាន អ្នកអាចផ្តោតលើវត្ថុបំណងនៃមេរៀន ជាក់លាក់។ ជាទូទៅ អ្នកអាចទាញវាបានពីក្នុងសៀវភៅសិក្សាគោល ឬយកខ្លះចេញពីសៀវភៅសិក្សាគោល។ អ្វីដែលសំខាន់គួរចងចាំនោះគឺ សៀវភៅសិក្សាគោលគ្រាន់តែជាឧបករណ៍មួយប៉ុណ្ណោះ បើទោះជាវាបោះពុម្ពចេញដោយក្រសួងអប់រំក៏ដោយ។ វាកាន់តែងាយស្រួលកាលដែលអនុវត្តតាមលំដាប់លំដោយដែលមាននៅក្នុងសៀវភៅសិក្សាគោល ដើម្បីប្រាកដថាអ្នកនឹងមិនភ្លេចខ្លឹមសារសំខាន់ក្នុងសៀវភៅទាំងនោះ។ ប៉ុន្តែអ្នកអាចបត់បែន និងកែសម្រួលលំហាត់ និងសកម្មភាពនៅពេលដែលវាមានភាពពាក់ព័ន្ធ។ អ្នកក៏ត្រូវកែកំហុសដែលអ្នកបានប្រទះឃើញក្នុងសៀវភៅសិក្សាគោលទាំងនោះ។ គ្រូមួយចំនួនប្រហែលជាមានអារម្មណ៍ភ័យខ្លាចក្នុងការកែ តម្រូវកំហុសក្នុងសៀវភៅសិក្សាគោលព្រោះខ្លាចត្រូវបានគេស្តីបន្ទោស។ ប៉ុន្តែនេះជារឿងត្រឹមត្រូវនិងសមហេតុសមផលដែលអ្នកគួរធ្វើ ព្រោះវានឹងជៀសវាងបញ្ហាជាច្រើនពេលបង្រៀននៅក្នុងថ្នាក់រៀននិងផ្តល់ឱ្យអ្នកអាចសម្រេចបាននូវឧត្តមភាព ជំនួសឱ្យការធ្វើតែបង្គ្រប់កិច្ច។ ក្រៅពីនេះការធ្វើដូច្នេះមានន័យថាអ្នកកំពុងតែគោរពតាមគោលគំនិតនៃកម្មវិធីសិក្សា បើទោះជាមិនបង្ហាញជាលាយលក្ខណ៍អក្សរក៏ដោយ។

## វត្ថុបំណងដែលអាចសង្កេតបាន

វត្ថុបំណងមេរៀនគួរតែត្រូវបានបង្ហាញតាមរយៈការសង្កេត។ មិនមានគ្រូណាម្នាក់អាចអាន និងដឹងពីសភាពផ្លូវចិត្តរបស់សិស្សបានទេ។ វាគ្មានន័យអីសូម្បីបន្តិចកាលដែលនិយាយពីក្តីស្រឡាញ់របស់ពួកគេចំពោះមុខវិជ្ជាអក្សរសិល្ប៍ ឬពីភាពស្មោះត្រង់របស់គេ។ តែវាមានប្រយោជន៍កាលដែលនិយាយពីអាកប្បកិរិយាដែលអ្នករំពឹងទុកពីពួកគេ។ គ្រូបង្រៀនអាចសង្កេតមើលថាសិស្សមានភាពគួរសម ហើយថាពួកគេប្តេជ្ញាចិត្តចំពោះការងារ របស់ខ្លួនប៉ុន្តែពេលខ្លះវាមិនបានឆ្លុះបញ្ចាំងពីសភាពពិតចំពោះអារម្មណ៍ខាងក្នុងរបស់ពួកគេនោះទេ។

ជាឧទាហរណ៍ លោកគ្រូម្នាក់អាចកែលំហាត់អនុវត្ត តែមិនអាចសង្កេតមើលពីដំណើរការនៃការយល់ដឹងរបស់សិស្សបានទេ។គ្រប់វត្ថុបំណងមេរៀនត្រូវផ្សារភ្ជាប់ជាមួយនឹងការវាយតម្លៃជាក់លាក់មួយ។ គ្រូប្រងៀនជាច្រើនអាចមានអារម្មណ៍ថាពិបាកណាស់កាលដែលរៀបចំការវាយតម្លៃរាល់ពេលដែលខ្លួនកំពុងរៀបចំកិច្ចតែងការបង្រៀន។ ហើយពេលខ្លះរដ្ឋបាលសាលារៀនកំពុងជំរុញតាមការណែនាំនៃការគ្រប់គ្រងជាផ្លូវការបែបការិយាធិបតេយ្យទៅលើលទ្ធផលសិក្សារបស់សិស្ស។ យើងមិនលើកទឹកចិត្តគ្រូបង្រៀនឱ្យដាក់ពិន្ទុនិងធ្វើរបាយការណ៍ពីសិស្សរបស់ខ្លួនជារៀងរាល់ថ្ងៃដើម្បីធ្វើកំណត់ត្រាជូនសាលារៀននោះទេ។ ការធ្វើបែបនោះពិតជាហត់នឿយសម្រាប់គ្រូបង្រៀន ហើយលើសពីនោះទៀត វាជាការខ្ជះខ្ជាយពេលវេលាដែលនឹងបង្វែរពួកគាត់ពីការយកចិត្តទុកដាក់ក្នុងការបង្រៀនជាក់ស្តែងរបស់ខ្លួន។

និយាយពីចំណុចនេះ យើងគ្រាន់តែណែនាំនូវយុទ្ធសាស្ត្រសាមញ្ញមួយចំនួន ដើម្បីប្រាកដថា សិស្សយល់ពីខ្លឹមសារមេរៀនដែលបង្រៀន។ វាគួរតែជាវិធីដែលរហ័សហើយមានលក្ខណៈសាមញ្ញបំផុត។ ជួនកាលនេះត្រូវបានគេ

ហៅថាជាការវាយតម្លៃបែបទម្រង់ឬតាមដំណាក់កាលទោះបីក្នុងការអនុវត្តជាក់ស្តែងភាពខុសគ្នាក្នុងការអនុវត្តទ្រឹស្តីនៃការវាយតម្លៃបែបដំណាក់កាល និងតាមបែបបូកសរុប ទំនងជាមានភាពមិនច្បាស់លាស់ក៏ដោយ។

គ្រូគួរពិនិត្យមើលការយល់ដឹងរបស់សិស្សរៀងរាល់១០នាទីម្តង។ នេះគឺជាជម្រើសមួយចំនួនដើម្បីចំណេញ ពេលវេលា៖

- ការសួរសំណួរទៅកាន់សិស្សដែលបានជ្រើសរើសដើម្បីពិនិត្យមើលថាតើពួកគេយល់វាក្យសព្ទនៃមេរៀនដែរឬទេ។
- ស្នើសុំឱ្យសិស្សលើកជាឧទាហរណ៍។
- ស្នើសុំឱ្យសិស្ស សរសេរចម្លើយនៅលើក្តារឆ្នួន។
- ស្នើសុំឱ្យសិស្សធ្វើលំហាត់មួយហើយចល័តពីតុមួយទៅតុមួយ ដើម្បីពិនិត្យមើលថាតើពួកគេធ្វើបាន ដែរឬទេ។

តាមអ្វីដែលអ្នកអាចឃើញ មិនមានអ្វីស្មុគស្មាញ ឬត្រូវចំណាយពេលវេលាក្នុងការអនុវត្តវិធីទាំងអស់នេះទេ។ ប៉ុន្តែគ្រូបង្រៀនត្រូវដឹងពីបំណងដែលខ្លួនចង់ធ្វើ។ បើគ្មានផែនការត្រឹមត្រូវទេ គ្រូបង្រៀនអាចនិយាយពីរឿងដែលមិនទាក់ទិននឹងមេរៀនពេញមួយម៉ោង និងដោយមិនបានសម្គាល់ថាសិស្សបាត់នូវចំណាប់អារម្មណ៍ក្នុងការរៀន។

## ពន្យល់ពីវត្ថុបំណងមេរៀនទៅកាន់សិស្ស

សូមប្រុងប្រយ័ត្ន វត្ថុបំណងមេរៀនដែលអ្នកបានកំណត់ ហើយគិតថាច្បាស់លាស់, អាចនឹងធ្វើឱ្យសិស្សយល់ច្រឡំឬមិនយល់។ ប្រសិនបើអាចនៅពេលអ្នកប្រាប់ពីវត្ថុបំណងមេរៀន សូមកុំប្រើពាក្យបច្ចេកទេសដែលអ្នកនឹងយកមកបង្រៀន។ ចូរព្យាយាមប្រើពាក្យដែលសិស្សអាចយល់បាន។ ជាការពិត អ្នកនឹងណែនាំពាក្យថ្មីដល់ពួកគេ ប៉ុន្តែគួរប្រើពាក្យថ្មីក្នុងអំឡុងពេលបង្រៀន បន្ទាប់ពីបានពន្យល់ក្នុងស្ថានភាពណាមួយដែលត្រូវការប្រើពាក្យទាំងនោះទៅសិស្ស។ ជាឧទាហរណ៍ កុំនិយាយប្រាប់សិស្សថាអ្នកនឹងសិក្សាពីទ្រឹស្តីបទតាឡេស។ ផ្ទុយទៅវិញ សូមប្រាប់សិស្សថា ពួកគេនឹងរៀនពីរបៀបគណនាកម្ពស់របស់វត្ថុធំៗ នៅពេលដែលវាមិនអាចវាស់បានដោយផ្ទាល់។

នៅពេលដែលមានការវាយតម្លៃសំខាន់ត្រូវបានអនុវត្ត ជាឧទាហរណ៍ ការសរសេរសំណេរតែងសេចក្តី ឬផលប័ត្រ (Portfolio) វាជាការល្អដែលគ្រូគួរណែនាំដល់សិស្សនៅពេលចាប់ផ្តើមជំពូកមេរៀន ឬវារិតតែប្រសើរជាងនេះនៅដើមឆ្នាំសិក្សា ដើម្បីកុំឱ្យសិស្សភ្ញាក់ផ្អើល ដើម្បីកែលម្អការអនុវត្តរបស់ពួកគេ និងជៀសវាងភាពអន្ទះសារផងដែរ។

## អាចធ្វើបាន

មធ្យោបាយដ៏សាមញ្ញមួយក្នុងការរចនាវត្ថុបំណងមេរៀនឱ្យបានល្អ និងដើម្បីធ្វើហួសពីបញ្ជីនៃប្រធានបទ គឺត្រូវចាប់ផ្តើមឃ្លារបស់អ្នកជាមួយ "នៅចុងបញ្ចប់នៃមេរៀននេះ សិស្សអាច..."

## ប្លូមតាក់សូណូមី

មានវិធីផ្សេងគ្នាដើម្បីចាត់ថ្នាក់ និងរៀបចំវត្ថុបំណងមេរៀន។ ការចាត់ថ្នាក់ផ្សេងៗត្រូវបានស្នើឡើងដើម្បីធានាថា គ្រូបង្រៀនមិនភ្លេចខ្លឹមសារមេរៀនសំខាន់ៗ។ វាគួរតែលើសពីធាតុដែលដាក់ក្នុងកម្មវិធីសិក្សា (ចំណេះដឹងលើខ្លឹមសារ)ប៉ុន្តែរួមបញ្ចូលនូវអ្វីដែលសិស្សអាចធ្វើបានជាមួយនឹងចំណេះដឹងខ្លឹមសារទាំងនោះ និងកម្រិតណា ដែលពួកគេអាចឆ្លុះបញ្ចាំងពីវាបាន។ ជាការចាំបាច់ណាស់សម្រាប់គ្រូក្នុងការជួយជំរុញសិស្សឱ្យលើសពីការទន្ទេញចាំ ទៅដល់ការឆ្លុះបញ្ចាំងពីខ្លឹមសារនៃមេរៀននីមួយៗ។ យើងកំពុងអប់រំមនុស្សឱ្យមានបញ្ញា មិនមែនចាំដូចសត្វសេកដែលមិនចេះគិតនោះទេ។ ដើម្បីសម្រេចបានគ្រូបង្រៀនត្រូវយល់ដឹងឱ្យបានច្បាស់ការប្រើប្រាស់កិរិយាស័ព្ទប្លូមទាំង៦កម្រិត (ចងចាំ យល់ដឹង អនុវត្ត វិភាគ វាយតម្លៃ និងបង្កើតថ្មី) នៃទ្រឹស្តីប្លូមតាក់សូណូមី។

បេនចាមីនប្លូមគឺជាចិត្តសាស្ត្រវិទូដែលបានស្នើឱ្យមានការចាត់ថ្នាក់នៃវត្ថុបំណងអប់រំនៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៥០ ដូច្នេះអ្នកអប់រំអាចនិយាយភាសាតែមួយ និងមានភាពស៊ីសង្វាក់គ្នានៅក្នុងកម្មវិធីសិក្សា និងការវាយតម្លៃរបស់ពួកគេ។ ប្លូមតាក់សូណូមីត្រូវបានកែសម្រួលក្នុងឆ្នាំ ២០០១ ដោយគណៈកម្មាធិការមួយដែលដឹកនាំដោយ ឡូរិនអេនឌឺស៊ុន (Lorin Anderson)។

ប្លូមតាក់សូណូមីមានភាពស្មុគស្មាញ។ យើងសូមបង្ហាញតែប្លូមតាក់សូណូមីដែលបានកែសម្រួល (Revised Bloom) នៃផ្នែកចំណេះដឹង ឬវិជ្ជាសម្បទា

(Cognitive Domain) ដែលមានសារៈសំខាន់បំផុតនៅ ក្នុងថ្នាក់រៀន។ វាមានអត្ថប្រយោជន៍ក្នុងការប្រើកិរិយាស័ព្ទ ដើម្បីចាត់ថ្នាក់សកម្មភាពយល់ដឹងរបស់សិស្ស។ កិរិយាស័ព្ទទាំងនោះត្រូវបានរៀបចំដោយកម្រិតនៃភាពស្មុគស្មាញ។

- ✓ **លំដាប់នៃការគិតកម្រិតទាប** (Lower Order Thinking Skills) ៖
    - ចងចាំ
    - យល់ដឹង
    - អនុវត្ត
- ✓ **លំដាប់នៃការគិតកម្រិតខ្ពស់** (Higher Order Thinking Skills) ៖
    - វិភាគ
    - វាយតម្លៃ
    - បង្កើតថ្មី។

នៅពេលកំណត់វត្ថុបំណងមេរៀន ឬរៀបចំការវាយតម្លៃផ្សេងៗវាជារឿងសំខាន់ក្នុងការរៀបចំផែនការសកម្មភាព ឱ្យបានគ្រប់កម្រិតទាំងអស់របស់ប្លូមតាក់សូណូមី ។ គ្រូបង្រៀនមិនគួរគិតថា ការគិតកម្រិតខ្ពស់ សំខាន់ជាងការគិតកម្រិតទាបរបស់ប្លូមនោះទេព្រោះការគិតកម្រិតទាបបានជួយបំពេញបន្ថែមទៅលើការគិតកម្រិតខ្ពស់។ យើងមិនអាចមានគំនិតច្នៃប្រឌិតដោយមិនចាំពីការពិតជាច្រើននោះទេ។ យើងមិនអាចវាយតម្លៃសុពលភាពនៃព័ត៌មានទាំងមូលដោយមិនប្រៀបធៀបវាជាមួយនឹងការពិតពីមុនដែលយើង

យល់បានល្អនិងដែលយើងចងចាំដោយមិនស្ទាក់ស្ទើរនោះទេ។ លំដាប់នៃការគិតមិនត្រូវបានបង្ហាញតាម លំដាប់លំដោយដែរ។ អ្នកត្រូវយល់ពីគោលគំនិតមួយ មុននឹងអ្នកអាចទន្ទេញវាបានយ៉ាងមានស្ទាត់ជំនាញ។ ប៉ុន្តែអ្នកត្រូវទន្ទេញចាំការពិតឱ្យបានច្រើន ប្រសិនបើអ្នកចង់យល់ពីគំនិតស្មុគស្មាញ។ លំដាប់នៃការគិតផ្សេងៗគាំទ្រគ្នាទៅវិញទៅមកហើយក្នុងការបង្រៀននិង ការរៀន អ្នកគួរត្រឡប់ទៅវិញទៅមក ពីមួយទៅមួយ។

ទ្រឹស្តីរបស់ប្លូមក៏មានការរិះគន់ពីសំណាក់អ្នកប្រាជ្ញផ្សេងទៀតផងដែរ (ដូចជាការចាត់ថ្នាក់ផ្សេងទៀត) ប៉ុន្តែបើទោះជាមានការរិះគន់ក៏ដោយវានៅតែមានអត្ថប្រយោជន៍ក្នុងការអនុវត្ត។ វាអាចត្រូវបានប្រើក្នុងតារាងផែនការតេស្តដើម្បីធ្វើឱ្យការវាយតម្លៃមានតុល្យភាពនិងមានលក្ខណៈពេញលេញ។

| មាតិកា | ចងចាំ | យល់ដឹង | អនុវត្ត | វិភាគ | វាយតំលៃ | បង្កើតថ្មី |
|---|---|---|---|---|---|---|
| វាក្យស័ព្ទ | ✓លំហាត់ ទី ១ (សំណួរពហុជ្រើសរើស) | | | | | |
| អំណាន (រឿងប្រលោមលោក) | ✓លំហាត់ ទី ២ (ពន្យល់) | ✓លំហាត់ ទី ២ (ពន្យល់) | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| វេយ្យាករណ៍ | | | ✓លំហាត់ទី៣ (ការប្រកប) | | | |
| ប្រភេទអក្សរសាស្ត្រ | | | | ✓សំណេរតែងសេចក្តី | ✓សំណេរតែងសេចក្តី | ✓សំណេរតែងសេចក្តី |

## **ការសរសេរវត្ថុបំណងមេរៀនតាមគំរូ** KSA

## (**វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា**)

វិធីសាស្ត្រមួយទៀតគឺត្រូវបែងចែកវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា។ ការចាត់ថ្នាក់នោះមានភាពងាយស្រួលក្នុងការយល់ និងលើកកម្ពស់ការអប់រំបែបអនុវត្ត។

ពាក្យថា វិជ្ជាសម្បទា ឬ**ចំណេះដឹង (Knowledge)** គឺមានន័យត្រង់ ដែលសំដៅដល់បញ្ជីនៃការយល់ដឹង គំនិត និងការពិតផ្សេងៗដែលសិស្សត្រូវរៀន។ នេះជាអ្វីដែលគ្រូមានក្នុងចិត្តដោយឯកឯង ហើយអ្នកអាចស្វែងរកវាបានយ៉ាងងាយស្រួលនៅក្នុងកម្មវិធីសិក្សា ឬក្នុងសៀវភៅសិក្សាគោល។ ប៉ុន្តែពេលខ្លះ ខ្លឹមសារ ពិតប្រាកដមិនមានអត្ថន័យខ្លាំងទេ នោះមានន័យថាប្រធានបទ និងការពិតមួយចំនួនមានលក្ខណៈខុសប្រក្រតី និងអាចផ្លាស់ប្តូរ

បាន។ ជាឧទាហរណ៍ វាមិនមានបញ្ហាអ្វីជាដុំកំភួននោះទេ ប្រសិនបើសិស្សអានរឿងរបស់អ្នកនិពន្ធម្នាក់ ឬអ្នកផ្សេងទៀត។ ពួកគេនឹងរៀនបានច្រើនជាងមុនដោយផ្តោតលើការងាររបស់អ្នកនិពន្ធ ស្សេកស្ពែរ (Shakespeare) ឬលើការងាររបស់អ្នកនិពន្ធ វិចទ័រ យូហ្គូ (Victor Hugo)។ នៅពីក្រោយគំនិតគោលនៃមេរៀនទាំងនេះជាការសំខាន់ គ្រូគួរពិចារណាពីអ្វីដែលសិស្សអាចធ្វើបានស្របនឹងចំណេះដឹងដែលពួកគេមានស្រាប់។ នេះគឺជាអ្វីដែលយើងហៅថា **បំណិន ឬជំនាញ។** ជំនាញទាំងនោះអាចប្រើដោយដៃ អនុវត្តជាក់ស្តែង ឬប្រើបញ្ញា។ ជំនាញសរសេរនិងការត្រិះរិះពិចារណាគឺសំខាន់ជាងការចងចាំឈ្មោះតួអង្គក្នុងប្រលោមលោកដូចជា *Lord of the Flies*។ គោលបំណងពិតគឺដើម្បីឱ្យសិស្សអាចវិភាគអត្ថន័យបានស៊ីជម្រៅនៃប្រលោមលោកនេះ។

ចរិយាសម្បទា ឬឥរិយាបទ កម្រចាត់ជាការផ្តោតសំខាន់នៃមេរៀនមួយ ប៉ុន្តែអាចជាលទ្ធផលដែលទទួលបានក្រោយមេរៀន។ នេះមិនមែនមានន័យថា ចរិយាសម្បទា មានតម្លៃទាបជាងជំនាញសិក្សាផ្សេងនោះទេ។ ការអប់រំសីលធម៌មានសារៈសំខាន់ដូចទៅនឹងការអប់រំភាពឆ្លាតវៃដែរ។ ប៉ុន្តែចរិយាសម្បទាដែលយើងចង់បណ្តុះទាក់ទងទៅនឹងខ្លឹមសារមេរៀនតិចតួច និងកម្រជាប្រធានបទផ្ទាល់នៃមេរៀនបង្រៀនណាស់។ វាអាចសម្រេចបានតាមរយៈកម្មវិធីសិក្សាទាំងមូលដោយបង្កើតទម្លាប់ជាជាងបង្រៀនជាមេរៀនផ្ទាល់ដល់សិស្ស។

វត្ថុបំណងនៃចរិយាសម្បទាគួរតែត្រូវបានសរសេរជាអាកប្បកិរិយាដែលអាចសង្កេតបាន។ ជាឧទាហរណ៍ ការស្រលាញ់ប្រទេសជាតិ មិនមែនជាអ្វីដែល

យើងអាចពិនិត្យបានទេ។ ដូចឃ្លាដែលបានលើកឡើងខាងលើ សភាពចិត្ត របស់សិស្សមិនអាចដឹងបានដោយសង្កេតទេ។ ប៉ុន្តែយើងអាចសង្កេតមើល ថាតើសិស្សបង្ហាញការគោរពចំពោះបាវចនាជាតិរបស់ខ្លួនដែរឬទេ ថាតើពួក គេមានភាពគួរសម និងចេះជួយមិត្តរួមថ្នាក់របស់ខ្លួនជាដើម។

ទោះបីជាវាមើលទៅមានលក្ខណៈសិប្បនិម្មិតបន្តិចក្នុងការកំណត់វត្ថុបំណង មេរៀនតាមគំរូ KSA ក្នុងមេរៀននីមួយៗក៏ដោយ គំរូនេះបានជួយគ្រូបង្រៀន ក្នុងការផ្តល់នូវការអប់រំពេញលេញដោយមិនភ្លេចពីធាតុសំខាន់ៗទាំងបីនោះ ។ វាគឺជាវិធីសាស្ត្រដ៏ល្អមួយក្នុងការរៀបចំផែនការនៃជំពូកមេរៀនទាំងមូល ឬកម្មវិធីសិក្សាលម្អិតប្រចាំឆ្នាំ។

## ការរចនាសកម្មភាព

ដើម្បីជ្រើសរើសវិធីសាស្ត្របង្រៀន និងដើម្បីរៀបចំសកម្មភាពសិក្សា វាជា ការងាយស្រួលក្នុងការដឹងអំពីធាតុ (variables) សំខាន់ៗដែលអ្នកអាចកែ សម្រួលបាន។ យើងអាចបែងចែកជា ៣ ប្រភេទក្នុងចំណោមធាតុទាំងនោះ ដូចជា ខ្លឹមសារ (content), ដំណើរការ (process) និងលទ្ធផល (product)។

## ខ្លឹមសារមេរៀន

ខ្លឹមសារមេរៀន គឺជាអ្វីដែលអ្នកចង់ឱ្យសិស្សរៀន ឬជាប្រធានបទ។ ជាទូទៅ នេះគឺជាអ្វីដែលអ្នកសរសេរនៅពេលអ្នកត្រៀមមុនបង្រៀន។ ប្រសិនបើអ្នក ស៊ាំជាមួយមុខវិជ្ជារបស់អ្នក នោះអ្នកប្រហែលជាគិតថា វាមិនសំខាន់ពេក

នោះទេក្នុងការពិនិត្យមើលវាម្តងទៀត។ វាអាស្រ័យលើការសម្រេចចិត្តរបស់អ្នក ថាតើអ្នកចង់សរសេរខ្លឹមសារនៃមេរៀននោះឱ្យមានភាពលម្អិតដល់កម្រិតណា។ ជាការពិតណាស់ វាអាចចំណាយពេលច្រើនបន្តិច។ ដូច្នេះអ្នកគួរតែសរសេរឱ្យគ្រប់គ្រាន់តាមតម្រូវការ ប៉ុន្តែកុំឱ្យលើសពីភាពចាំបាច់។ ប្រសិនបើអ្នកកំពុងអនុវត្តសកម្មភាពបែបសិស្សសកម្ម (student-centered activities) វាអាចនឹងមានហានិភ័យធ្ងន់ធ្ងរកើតឡើង ព្រោះសិស្សរបស់អ្នកនឹងមានចម្លើយដែលអ្នកមិនបានរំពឹងទុកជាមុន។ សកម្មភាពទាំងនោះក៏អាចមានការលំបាកក្នុងការកំណត់អាទិភាពលទ្ធផលសិក្សា (learning outcomes)ចំពោះអ្នកផងដែរ។ ហេតុដូច្នេះហើយ វាជារឿងសំខាន់សម្រាប់អ្នកក្នុងការរៀបចំខ្លឹមសារសង្ខេបមេរៀននៃចំណុចសំខាន់ៗដែលអ្នកចង់ឱ្យពួកគេចងចាំ។

## ដំណើរការ

**ដំណើរការ គឺជារបៀបដែលសិស្សគួរតែរៀន ឬធ្វើកិច្ចការ។ទិដ្ឋភាពសំខាន់នោះគឺ អន្តរកម្មរវាងសិស្សនិងគ្រូ៖**

- ការបង្រៀន
- ការធ្វើការងារបុគ្គលដោយការកត់ត្រា (ជាលាយលក្ខណ៍អក្សរ)
- ការឆ្លើយសំណួរជាបុគ្គល និងផ្ទាល់មាត់
- ការឆ្លើយព្រមគ្នា

- ការពិភាក្សាពេញថ្នាក់
- ការធ្វើការងារជាដៃគូ
- ការធ្វើការងារជាក្រុម
- ការជជែកដេញដោល ឬតស៊ូមតិ ។ល។

អន្តរកម្មនីមួយៗមានគុណសម្បត្តិ និងគុណវិបត្តិរបស់វា។ វានឹងប្រើពេលយូរក្នុងការពិនិត្យមើលជម្រើសទាំងអស់នៅទីនេះ។ ដើម្បីជ្រើសរើសប្រភេទអន្តរកម្មដ៏ល្អបំផុត សូមចាំថា អ្នកចង់បង្កើនចំនួនសិស្សដែលសកម្មឱ្យបានច្រើនបំផុត ហើយនៅចុងបញ្ចប់មេរៀន សិស្សម្នាក់ៗត្រូវតែអាចធ្វើកិច្ចការនោះបាន។ វាត្រូវបានណែនាំឱ្យផ្លាស់ប្តូរប្រភេទនៃអន្តរកម្ម។ ហើយធ្វើការវាយតម្លៃជាលក្ខណៈបុគ្គល។ ជាមួយបទពិសោធន៍នេះ អ្នកគួរតែអាចបង្កើតជម្រើសដែលពាក់ព័ន្ធឱ្យបានកាន់តែប្រសើរ សម្រាប់សកម្មភាពនីមួយៗ។

ទិដ្ឋភាពមួយទៀតនៃដំណើរការគឺជារបៀបដែលសិស្សគួរតែទទួលបានខ្លឹមសារនៃមេរៀន។ តាមបែបប្រពៃណី គ្រូនឹងផ្តល់ខ្លឹមសារនៃមេរៀនដោយការបង្រៀនតាមបែបឧទ្ទេសដល់សិស្ស។ ប៉ុន្តែមានជម្រើសជាច្រើនទៀតដែលត្រូវពិចារណាផងដែរសម្រាប់អ្នក៖

- ការផ្តល់ឯកសារមួយចំនួនដែលមានព័ត៌មានសម្រាប់សិស្សធ្វើសកម្មភាព។
- ការស្នើសុំឱ្យសិស្សអានខ្លឹមសារមេរៀនក្នុងសៀវភៅសិក្សាគោល។
- ការអនុញ្ញាតឱ្យសិស្សធ្វើការពិសោធន៍ ឬឆ្លុះបញ្ចាំងដោយខ្លួនឯង។

- ការឱ្យសិស្សធ្វើការស្រាវជ្រាវតាមរយៈសៀវភៅផ្សេងៗ ឬតាមប្រព័ន្ធអ៊ីនធឺណិត។

វិធីសាស្ត្រនីមួយៗមានគុណសម្បត្តិ និងគុណវិបត្តិរបស់វា។ ប៉ុន្តែដូចដែលអ្នកបានឃើញ ការសិក្សាតាមបែបសកម្ម ដែលសិស្សធ្វើការដោយខ្លួនឯងអាចផ្តល់ព័ត៌មានបានច្រើនដូចជាការបង្រៀនតាមបែបឧទ្ទេស (lecture) ប្រសិនបើពួកគេត្រូវបានផ្តល់ឯកសារជំនួយគ្រប់គ្រាន់។ អ្វីដែលគ្រូត្រូវធ្វើ គឺរៀបចំផែនការសកម្មភាពល្អមួយ ដែលនឹងតម្រូវឱ្យពួកគេអានឯកសារជំនួយទាំងនោះយ៉ាងយកចិត្តទុកដាក់ និងផ្តល់នូវការកែតម្រូវដើម្បីធានាថាពួកគេនឹងមិនចងចាំខ្លឹមសារខុសនោះទេ។



## លទ្ធផល

លទ្ធផលគឺជាទម្រង់ស្នាដៃរបស់សិស្សនឹងលេចចេញនៅចុងបញ្ចប់នៃសកម្មភាព។ ឧទាហរណ៍ វាអាចជាលំហាត់ខ្លីនៅក្នុងសៀវភៅសរសេរ របាយការណ៍ ផ្ទាំងរូបភាព (poster) វីដេអូ ការថតសំឡេង រូបភាព ការសម្ដែងតួជាដើម។ មានជម្រើសច្រើនគ្មានដែនកំណត់។

ជាជម្រើសដ៏ឆ្លាតវៃអ្នកគួរតែពិចារណាលើវត្ថុបំណងនិងឧបសគ្គមួយចំនួន។ ចូរចាំថា ការរៀនសូត្ររបស់សិស្សគឺជាគោលបំណងចម្បងរបស់អ្នកដែលជាគ្រូបង្រៀន។ ការរចនាផ្ទាំងរូបភាពដ៏ស្រស់ស្អាតសម្រាប់ការតាំងពិព័រណ៍ (Parent Exhibition) គ្រាន់តែជាមធ្យោបាយប៉ុណ្ណោះ។

កុំស្ទាក់ស្ទើរក្នុងការផ្ដល់នូវឧទាហរណ៍ពីអ្វីដែលអ្នកចង់បាន ទោះបីជាវាប្រើពេលច្រើនក្នុងការធ្វើជាគំរូក៏ដោយ។ ជាថ្មីម្ដងទៀត អ្នកគ្រាន់តែចាត់ទុកវាជាការវិនិយោគដ៏ល្អមួយ។ នៅពេលអ្នកធ្វើសកម្មភាពដដែលៗជាមួយសិស្សថ្នាក់ផ្សេង នោះអ្នកអាចប្រើបទពិសោធន៍ល្អបំផុតពីថ្នាក់មុន ដើម្បីពន្យល់ដល់ថ្នាក់ផ្សេងៗទៀត។ វាជាវិធីល្អមួយដើម្បីកំណត់ស្តង់ដា និងជាការលើកកម្ពស់គុណភាព។

## ការប្រើ បញ្ញាសិប្បនិម្មិតដើម្បីរចនាកិច្ចតែងការបង្រៀន

យើងត្រូវទទួលស្គាល់ថា បញ្ញាសិប្បនិម្មិតបានរីកចម្រើនយ៉ាងខ្លាំងក្នុងរយៈពេលពីរបីឆ្នាំចុងក្រោយមកនេះ។ ឥឡូវនេះ ពួកវាបានឈានដល់ការពេញនិយម ព្រោះអាចសន្សំសំចៃពេលវេលាបានច្រើនសម្រាប់បុគ្គលិកឆ្លាតវៃដែលប្រើប្រាស់វាជំនួសក្នុងការបំពេញកិច្ចការប្រចាំថ្ងៃដែលជាទម្លាប់ដដែល។ វាអាចជារឿងឆោតល្ងង់ប្រសិនបើយើងបដិសេធមិនប្រើឧបករណ៍ដ៏មានឥទ្ធិពលមួយនេះ ពេលនិយាយពីការរចនាកិច្ចតែងការបង្រៀន។ វាអាចបង្កើតកិច្ចតែងការបង្រៀនបានដោយខ្លួនឯងក្នុងរយៈពេលតែប៉ុន្មាននិនាទីប៉ុណ្ណោះ លើសពីនេះ វាក៏អាចបង្កើតជារូបភាពដើម្បីពន្យល់ពីគំនិត លំហាត់ និងសម្ភារៈបង្រៀនគ្រប់ប្រភេទផងដែរ។

ទោះបីជាបញ្ញាសិប្បនិម្មិតមានឥទ្ធិពលយ៉ាងណាក៏ដោយ គ្រោះថ្នាក់ជាក់ស្តែងមួយចំនួនអាចបង្កឡើង ហេតុនេះ គ្រូគួរយល់ដឹងអំពីវាបន្ថែម។ ការបង្កើតផែនការបង្រៀនទាំងស្រុងជាមួយបញ្ញាសិប្បនិម្មិតនឹងធ្វើឱ្យបាត់បង់គោលបំណងពិតប្រាកដនៃកិច្ចតែងការបង្រៀន ដូចដែលយើងបានលើកឡើងនៅដើមសៀវភៅតូចនេះ។ កិច្ចតែងការបង្រៀនគឺទាក់ទងនឹងការសម្រេចចិត្ត។ វាមិនសមហេតុផលទេក្នុងការបង្កើតកិច្ចតែងការបង្រៀនដោយមិនបានអានមេរៀនបង្រៀន។ ចូរកុំប្រថុយនឹងការរចនាកិច្ចតែងការបង្រៀន

ដោយគ្រាន់តែយល់ពីស្ថានភាពថ្នាក់រៀន ដែលមិនមានភាពជាក់លាក់។ ប្រសិនបើអ្នកជាមនុស្សខ្ជិលនិងចូលចិត្តប្រថុយបែបនេះ អ្នកអាចគ្រាន់តែបង្រៀនតាមសៀវភៅសិក្សាគោល ហើយសង្ឃឹមថា អ្នកនឹងមិនធ្វើឱ្យមាន

កំហុសធ្ងន់ធ្ងរណាមួយកើតឡើងក្នុងអំឡុងពេលបង្រៀននោះឡើយ។ យ៉ាងហោចណាស់ អ្នកត្រូវតែពិនិត្យមើលសម្ភារៈដែលត្រូវការសម្រាប់ការអនុវត្តពេលវេលាកំណត់ និងសួរសំណួរដោយខ្លួនឯងដើម្បីបញ្ជាក់។

បញ្ញាសិប្បនិម្មិត ដំណើរការតាមរយៈសារឆ្លើយតបដោយស្វ័យប្រវត្តិ (chatbot)។ មានន័យថា អ្នកត្រូវតែ "ពិភាក្សា" ជាមួយ បញ្ញាសិប្បនិម្មិតនេះ ដើម្បីកែលម្អចម្លើយរបស់វា និងទទួលបានអ្វីដែលអ្នកចង់បាន។ កិច្ចតែងការបង្រៀនដែលបង្កើតដោយ ឧបករណ៍នេះ អាចនឹងមានភាពរាយប៉ាយខ្លាំង។ វាទំនងជានឹងបង្កើតនូវគំនិតមិនច្បាស់លាស់ និងទូលំទូលាយភាគច្រើន ដែលអ្នកនឹងត្រូវបំពេញបន្ថែមដោយខ្លួនឯង។ ឧទាហរណ៍ បញ្ញាសិប្បនិម្មិត អាចណែនាំឱ្យប្រើវីដេអូដែលអ្នកត្រូវស្វែងរកតាមរយៈការស្វែងរកជាក់លាក់នៅលើ YouTube និងគេហទំព័រស្ថាប័ន។ ហេតុដូច្នេះហើយនៅតែមានកិច្ចការជាច្រើនដែលត្រូវធ្វើដោយខ្លួនអ្នកផ្ទាល់។ ទោះជាយ៉ាងណាក៏ដោយ បញ្ញាសិប្បនិម្មិត អាចជួយសម្រួលដល់ការងារដោយការណែនាំពីគេហទំព័រដែលពាក់ព័ន្ធ (ទោះបីជាគុណភាពនៃការណែនាំអាចប្រែប្រួលខ្លះក៏ដោយ)។ ជាក់ស្តែង អ្នកប្រហែលជាត្រូវការបណ្តុំបញ្ញាសិប្បនិម្មិតក្នុងការធ្វើកិច្ចការនេះ។ បញ្ញាសិប្បនិម្មិតខ្លះ អាចសង្ខេបឯកសារដែលអ្នកបានផ្តល់។ ខ្លះទៀតអាចបង្កើតផែនទីគំនិត (Mind-maps) ពីឯកសារដែលអ្នកស្នើ (ទោះបីជាវាអាចប្រសើរជាងបើធៀបនឹងផែនទីគំនិតដែលអ្នករចនា ដើម្បីពិនិត្យមើលកម្រិតយល់ដឹង)។ ឯបញ្ញាសិប្បនិម្មិតខ្លះទៀត ពូកែបង្កើតរូបភាពជាដើម។

ហានិភ័យចម្បងមួយទៀត គឺការទុកចិត្តលើបញ្ញាសិប្បនិម្មិតខ្លាំងពេក ជាពិសេសលើខ្លឹមសារនៃមេរៀន។ កម្មវិធីបញ្ញាសិប្បនិម្មិត មិនដំណើរការតាមរយៈការឆ្លុះបញ្ចាំងត្រឹមត្រូវអំពីប្រធានបទជាក់ស្តែងដែលយើងចង់បាននោះទេ។ បញ្ញាសិប្បនិម្មិតដែលគេបង្កើតមក គ្រាន់តែចងក្រងមូលដ្ឋានទិន្នន័យដ៏ធំនៅលើវា ហើយព្យាករណ៍អត្ថបទដែលមានកម្រិតសមស្របខ្ពស់បំផុតចំពោះការឆ្លើយតបនឹងការសួរពីអ្នកប្រើ។ វាមិនមានការយល់ដឹងពីការរកឃើញកំហុស ឬបទពិសោធន៍ក្នុងជីវិតពិតនោះទេ។ តាមពិត វាជាកំហុសមួយក្នុងការជឿថា បញ្ញាសិប្បនិម្មិតយល់នូវគ្រប់រឿងរ៉ាវទាំងអស់ ផ្ទុយមកវិញ វាគ្រាន់តែកំណត់លំនាំ និងធ្វើការតាមកម្រិតសមស្របតែប៉ុណ្ណោះ។ វាសរសេរពាក្យដែលមើលទៅទំនង និងត្រូវនឹង ការសួរសំណួរ (prompts) ដែលបានផ្តល់ឱ្យ។ ប្រសិទ្ធភាពរបស់វាអាស្រ័យលើគុណភាពនៃមូលដ្ឋានទិន្នន័យដែលមាន។ ប្រសិនបើមានកំហុសនៅក្នុងមូលដ្ឋានទិន្នន័យ វាក៏នឹងមានកំហុសនៅក្នុងអត្ថបទដែលបានបង្កើតដែរ។ លើសពីនេះទៅទៀត បញ្ញាសិប្បនិម្មិត មានកម្រិតលំអៀងក្នុងការបញ្ជាក់ (confirmation bias) ខ្ពស់។ វាអាចប្រាប់ពីអ្វីដែលពេញនិយមលើឯកសារដែលវាបានស្តេន។ ដូច្នេះហើយ តួនាទីរបស់អ្នកប្រើ គឺត្រូវពិនិត្យព័ត៌មាន និងកែតម្រូវកំហុសណាមួយដែលបង្កឡើងដោយបញ្ញាសិប្បនិម្មិត ព្រោះវាអាចមានភាពលំអៀង ឬភ័ន្តច្រឡំ។

ចម្លើយដំបូងបំផុតរបស់ បញ្ញាសិប្បនិម្មិត អាចមានភាពមិនច្បាស់លាស់ (crude) ហើយទំនងជាពោរពេញដោយគំនិតចាស់ៗ (clichés) និងការរើសអើង។ យើងអាចទទួលបានព័ត៌មានបន្ថែម ឬកែតម្រូវកំហុសមួយចំនួន

ដោយសួរសំណួរបន្ថែម ប៉ុន្តែអ្នកនឹងទទួលបានតែអ្វីដែលអ្នកបានសួរ។ អ្នកនឹងត្រូវការភាពស្ទាត់ជំនាញ និងការគិតស៊ីជម្រៅផ្ទាល់ខ្លួន ដើម្បីរៀបចំមេរៀន។ អ្នកចាំបាច់ត្រូវអានមេរៀនដើម្បីជម្រុះចោលនូវគំនិតមិនពិតមួយចំនួន។ ប្រសិនបើបញ្ញាសិប្បនិម្មិតផ្តល់ឯកសារយោងវាអាចមានប្រយោជន៍សម្រាប់អ្នកក្នុងការអានឯកសារដើម ដើម្បីធានាថា បញ្ញាសិប្បនិម្មិត មិនបានបកស្រាយខុស ជាពិសេស លើប្រធានបទដែលមានភាពចម្រូងចម្រាស។ ដូច្នេះហើយ អនុសាសន៍របស់យើងគឺអ្នកត្រូវព្រាងគម្រោងទូទៅនៃមេរៀនដោយខ្លួនឯង យ៉ាងហោចណាស់ ដើម្បីដឹងថាអ្នកចង់សួរបញ្ញាសិប្បនិម្មិតពីអ្វី ។ បន្ទាប់មក បញ្ញាសិប្បនិម្មិត អាចជួយអ្នកកំណត់ចំណុចសំខាន់ៗមួយចំនួនដែលអ្នកប្រហែលជាបានបំភ្លេច។ ឧបករណ៍នេះអាចណែនាំសកម្មភាពមួយចំនួន ដែលអ្នកមិនបានគិតទុកមុន។ ហើយអ្នកអាចរកឃើញចំណុចសំខាន់ៗដែល បញ្ញាសិប្បនិម្មិតអាចមើលរំលង។ អ្នកត្រូវចាត់ទុកបញ្ញាសិប្បនិម្មិត ជាឧបករណ៍បង្កើនល្បឿននៃការងាររបស់អ្នកមិនមែនជាល្បិចវេទមន្តដើម្បីលាក់បាំងភាពខ្ជិលរបស់អ្នកនោះទេ។

ម្យ៉ាងទៀត ប្រសិនបើអ្នកសួរសំណួរអំពីដែនកំណត់នៃបញ្ញាសិប្បនិម្មិតដែលល្អបំផុតមួយចំនួននៅលើទីផ្សារនោះវានឹងឆ្លើយប្រាប់ថាកុំទុកចិត្តវាខ្លាំងពេក ត្រូវពិនិត្យមើលព័ត៌មាន និងកែសម្រួលកិច្ចតែងការបង្រៀនឱ្យសមស្របតាមកាលៈទេសៈផ្ទាល់ខ្លួនរបស់អ្នក។

បញ្ញាសិប្បនិម្មិតមានប្រសិទ្ធភាព ជាពិសេសក្នុងការបង្កើតលំហាត់និងសំណួរតេស្តក្នុងចំនួនដ៏ច្រើន។ កិច្ចការនេះគួរឱ្យធុញទ្រាន់ចំពោះអ្នក ដូច្នេះ

អ្នកអាចទុកឱ្យបញ្ញាសិប្បនិម្មិតបង្កើតវាសម្រាប់អ្នក។ ទោះជាយ៉ាងណាក៏ដោយអ្នកត្រូវតែមានភាពច្បាស់លាស់អំពីប្រភេទសំណួរតេស្តដែលអ្នកចង់បាននិងមូលហេតុត្រឹមត្រូវ។ កុំភ្លេចបញ្ជាក់ទម្រង់ដែលអ្នកចង់បានពីការបង្កើតសំណួរដោយបញ្ញាសិប្បនិម្មិត ជាឧទាហរណ៍ សំណួរពហុជ្រើសរើស (MCQs) ជាមួយជម្រើសចម្លើយបន្លំចំនួន ៤ (4 distractors) ឬប្រភេទសំណួរបើក (open-ended questions) ជាមួយចម្លើយខ្លីៗ។ ចូរប្រាកដថា អ្នកទទួលបានសំណួរបញ្ចូលគ្នាយ៉ាងល្អ រវាងសំណួរបែបឆ្លុះបញ្ចាំង និងសំណួរបែបចងចាំ។ ជាការពិតណាស់ មិនខុសពីការធ្វើលំហាត់ក្នុងសៀវភៅសិក្សាគោល ក្នុងនាមជាគ្រូ អ្នកគួរតែព្យាយាមធ្វើលំហាត់ដោយដៃជានិច្ច បន្ទាប់ពីបង្កើតវាដោយបញ្ញាសិប្បនិម្មិត។ អ្នកគួរពិនិត្យមើលថា តើលំហាត់សំណួរអ្នកអាចធ្វើបានដែរឬទេ ហើយប្រសិនបើចម្លើយដែលរំពឹងទុកគឺត្រឹមត្រូវ។ ជាចុងក្រោយ ចូរកំណត់ពេលវេលាដែលសិស្សនឹងចំណាយពេលធ្វើលំហាត់ដែលអ្នកបានតេស្តរួចហើយ។

យើងសូមមិនណែនាំឱ្យប្រើបញ្ញាសិប្បនិម្មិតដើម្បីដាក់ពិន្ទុលើកិច្ចការរបស់សិស្សនោះទេ លុះត្រាតែតេស្តនោះជាទម្រង់ដែលមិនតម្រូវឱ្យមានការវិភាគល្អិតល្អន់ពីគ្រូ ដូចជា តេស្តសំណួរពហុជ្រើសរើស (MCQs) ជាដើម។ ទោះយ៉ាងណាក៏ដោយ គ្រូគួរចងចាំថា ការបង្កើតតេស្តដោយស្វ័យប្រវត្តិ មានកម្រិតសុពលភាពទាប (low validity)។ អ្វីដែលកាន់តែធ្ងន់ធ្ងរជាងនេះទៅទៀតនោះគឺ ការពឹងផ្អែកលើបញ្ញាសិប្បនិម្មិតជាអ្នកកែសំណួរបែបទម្រង់សំណេរអត្ថបទ ឬតែងសេចក្តី (essay) ។ ហេតុផលទី១ គឺជាការមិនផ្តល់តម្លៃដល់សិស្សដែលបានខិតខំសរសេរអត្ថបទពីគំនិតផ្ទាល់របស់ពួកគេ និង

ទី២ អ្នកនឹងមិនអាចផ្ដល់មតិកែលម្អបានត្រឹមត្រូវដែលអាចជួយសិស្សឱ្យប្រសើរឡើងបាននោះទេ ប្រសិនបើអ្នកមិនដឹងថាពួកគេបានសរសេរខ្លឹមសារពីអ្វី។ បញ្ញាសិប្បនិម្មិត នឹងមិនអាចរកឃើញបញ្ហាទាំងអស់ និងប្រើសតិអារម្មណ៍សម្រាប់ការវាយតម្លៃលើសំណេររបស់សិស្សបានដូចមនុស្ស (គ្រូ) នោះទេ។

អ្នកត្រូវប្រាកដថា អ្នកចំណាយពេលគ្រប់គ្រាន់ដើម្បីអនុវត្តជាមួយបញ្ញាសិប្បនិម្មិត មុនពេលអ្នកយកប្រើវាដើម្បីសម្រួលដល់មេរៀនបង្រៀនណាមួយជាក់ស្ដែង។ ប្រសិនបើអ្នកប្រើប្រាស់វាជាប្រចាំយើងក៏ណែនាំអ្នកឱ្យរៀនសាកល្បងឧបករណ៍ថ្មីម្ដងហើយម្ដងទៀតផងដែរ ព្រោះបច្ចេកវិទ្យា តាមការរចនា គឺស្ថិតក្នុងការវិវត្តន៍ឥតឈប់ឈរ។ គំនិតនៃបញ្ញាសិប្បនិម្មិតគឺការរៀនរបស់ម៉ាស៊ីន (machine learning)។ បញ្ញាសិប្បនិម្មិត តែងតែដំណើរការទិន្នន័យថ្មី មិនត្រឹមតែដោយការត្រួតពិនិត្យឯកសារថ្មីៗនៅលើប្រព័ន្ធអ៊ីនធឺណិតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរៀនពីអ្នកប្រើប្រាស់វាខ្លួនឯង និងមតិកែលម្អដែលពួកគេបានផ្ដល់ផងដែរ។ រាល់ពេលដែលអ្នកកែលម្អចម្លើយដោយសំណួរថ្មី វាជះឥទ្ធិពលដល់ដំណើរការរួមរបស់ បញ្ញាសិប្បនិម្មិតបន្តិចបន្តួចដែរ។ ចូរអ្នកប្រាកដក្នុងចិត្តថា អ្នកកំពុងប្រើឧបករណ៍ដែលមានសមត្ថភាពខ្ពស់បំផុត ហើយសំខាន់បំផុត នោះគឺជាឧបករណ៍ដែលគួរឱ្យទុកចិត្តបំផុត។

# ឧបករណ៍ផ្សេងៗ



**ឧបករណ៍ទី១៖** ការឆ្លុះបញ្ចាំងដោយខ្លួនឯង ( Self-Reflection )

- តើខ្ញុំមានអារម្មណ៍សប្បាយចិត្តកម្រិតណាជាមួយខ្លឹមសារនៃមុខវិជ្ជារបស់ខ្ញុំ ?
- តើខ្ញុំគួរពិនិត្យមើលព័ត៌មានមូលដ្ឋានប្រភេទណាខ្លះ ដើម្បីជៀសវាងភាពអាម៉ាស់ដែលអាចកើតនៅក្នុងថ្នាក់រៀន នៅពេលដែលមានសិស្សសួរ ដូចជា កាលបរិច្ឆេទ ឈ្មោះរូបមន្ត ?
- តើខ្ញុំនឹងត្រូវការចំណេះដឹងបន្ថែមអ្វីខ្លះ ក្នុងករណីដែលសិស្សរបស់ខ្ញុំសួរសំណួរ ? តើពួកគេអាច សួរនូវសំណួរប្រភេទណា ?
- តើខ្ញុំយល់ច្បាស់ពីនីតិវិធីនៃការប្រើវិធីសាស្ត្របង្រៀនដែលខ្ញុំគ្រោងយកទៅអនុវត្តដែរឬទេ ?
- តើមានចំណុចសំខាន់ៗអ្វីខ្លះដែលខ្ញុំអាចនឹងភ្លេចភ្លាំង ?
- តើខ្ញុំមានយុទ្ធសាស្ត្របែបណាខ្លះដើម្បីពិនិត្យមើលថាតើសិស្សរបស់ខ្ញុំយល់មេរៀនដែរឬទេ ?

**ឧបករណ៍ទី ២៖** សេចក្តីណែនាំពីការវាយតម្លៃលើកិច្ចតែងការបង្រៀន

| |
|---|
| ឈ្មោះអ្នកសង្កេត៖ |
| ឈ្មោះគ្រូ៖ |
| មុខវិជ្ជា៖ |
| ថ្នាក់៖ |
| កាលបរិច្ឆេទ៖ |
| ចំណងជើងមេរៀន៖ |

ទម្រង់នេះមានគោលបំណងសម្រួលដល់ការវាយតម្លៃកិច្ចតែងការបង្រៀន និងផ្តល់មតិកែលម្អដល់គ្រូ។ ជាទូទៅវាត្រូវបានប្រើប្រាស់ដោយគ្រូប្រឹក្សាគរុកោសល្យ (mentor) ឬនាយកសាលាដើម្បីវាយតម្លៃគុណភាពនៃការត្រៀមរៀបចំមេរៀនតាមវត្ថុបំណងច្បាស់លាស់។ វាត្រូវបានគេហៅថាជាឧបករណ៍វាយតម្លៃដោយខ្លួនឯង។ អ្នកអាចប្រើវាបានទាំងមុន និងក្រោយពេលបង្រៀនមេរៀន។ វិធីល្អមួយដើម្បីវាយតម្លៃគុណភាពនៃការត្រៀមរៀបចំមេរៀនរបស់អ្នកគឺការប្រៀបធៀបការរំពឹងទុកជាមួយនឹងការអនុវត្តជាក់ស្តែង។

វាមិនមែនជាបញ្ជីត្រួតពិនិត្យ (checklist) ហើយក៏មិនមែនជាការជំនួសកិច្ចតែងការនោះទេ។ ចំណុចយកចិត្តទុកដាក់ដែលបានលើកឡើងនៅក្នុងនិទ្ទេសបទ (rubric) មិនទូលំទូលាយទេ។ ស្រដៀងគ្នានេះដែរ ចំណុចមួយចំនួនអាចនឹងមិនពាក់ព័ន្ធនៅគ្រប់មេរៀននោះទេ ដូច្នេះមិនចាំបាច់ត្រូវវាយតម្លៃដែរ។ សូមកត់សម្គាល់រាល់អ្វីដែលគួរលើកឡើង។ ទាំងការអនុវត្តល្អនិងមិនល្អ ត្រូវបានពិចារណា។

សូមផ្តល់ការវាយតម្លៃទូទៅនៃនិទ្ទេសបទនីមួយៗ (rubric) មិនមែនពិន្ទុជាលេខទេ៖

- ខ្សោយ (Poor) (ចាំបាច់ត្រូវមានការកែលម្អខ្លាំងបំផុត)
- ទទួលយកបាន (Satisfying) (ការអនុវត្តអាចទទួលយកបាន ទោះបីជាការកែលម្អខ្លះគួរត្រូវកែលម្អក៏ដោយ)
- ល្អ (Good) (មិនចាំបាច់មានការកែលម្អភ្លាមៗនោះទេ)
- ល្អណាស់ (Very good) (ការអនុវត្តរបស់គ្រូអាចត្រូវបានណែជាគំរូ)

- សូមផ្តល់ការពិពណ៌នាលម្អិត។ ជួរឈរនេះគឺសំខាន់បំផុត ព្រោះគោលបំណងនៃទម្រង់វាយតម្លៃគឺដើម្បីផ្តល់ព័ត៌មានដល់គ្រូអំពីចំណុចដែលត្រូវកែលម្អ។

| និទ្ទេសបទ | | ការសង្កេត | |
|---|---|---|---|
| | | ការវាយតម្លៃ * | មតិយោបល់ |
| ការអនុវត្ត | ជាឧទាហរណ៍ កិច្ចតែងការបង្រៀន៖<br>● សាមញ្ញគ្រប់គ្រាន់<br>● មានព័ត៌មានដែលចាំបាច់<br>● មិនមានព័ត៌មានឥតពាក់ព័ន្ធ។ | ខ្សោយ<br>ទទួលយកបាន<br>ល្អ<br>ល្អណាស់ | |
| វត្ថុបំណងមេរៀន | ជាឧទាហរណ៍ វត្ថុបំណងមេរៀន៖<br>● សាមញ្ញងាយយល់<br>● មានចំណុចសំខាន់៣ (វិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា )<br>● មានភាពចម្រុះនៃកម្រិតប្លូម | ខ្សោយ<br>ទទួលយកបាន<br>ល្អ<br>ល្អណាស់ | |
| ខ្លឹមសារ | ជាឧទាហរណ៍ ខ្លឹមសារ៖<br>● មានភាពស៊ីជម្រៅគ្រប់គ្រាន់<br>● មានសុពលភាពបែបវិទ្យាសស្ត្រ<br>● សមស្របនឹងកម្រិតសម្ថភាពរបស់សិស្ស | ខ្សោយ<br>ទទួលយកបាន<br>ល្អ<br>ល្អណាស់ | |

| | | | |
|---|---|---|---|
| សកម្មភាព | ជាឧទាហរណ៍៖<br>• ភាពសម្បូរបែប<br>• គ្មានសិស្សអសកម្ម<br>• ការណែនាំច្បាស់លាស់<br>• ការកំណត់ច្បាស់លាស់៖ បុគ្គល ក្រុមតូច ថ្នាក់ទាំងមូល | ខ្សោយ<br>ទទួលយកបាន<br>ល្អ<br>ល្អណាស់ | |
| ការវាយតម្លៃតាមដំណាក់ ឬតាមទម្រង់ | ជាឧទាហរណ៍៖<br>• ការកំណត់អត្តសញ្ញាណនៃគំនិតសំខាន់ៗ និងគំនិតពិបាកៗ ដែលត្រូវត្រួតពិនិត្យ<br>• ភាពសាមញ្ញ និងប្រសិទ្ធភាព<br>• ភាពញឹកញាប់ល្អ (រៀងរាល់ ៥ ឬ ១០ នាទី)<br>• សិស្សក្នុងថ្នាក់ត្រូវបានវាយតម្លៃ | ខ្សោយ<br>ទទួលយកបាន<br>ល្អ<br>ល្អណាស់ | |

**ឧបករណ៍ទី ៣៖ ទម្រង់គំរូនៃកិច្ចតែងការបង្រៀន** (Templates of Lesson Plans) រដ្ឋបាលសាលា ឬវិទ្យាស្ថានបណ្តុះបណ្តាលគ្រូ (TTI) អាចផ្តល់ឱ្យអ្នកនូវទម្រង់គំរូមួយ។ ទោះជាយ៉ាងណាក៏ដោយ វាជារឿងសំខាន់សម្រាប់អ្នកក្នុងការប្រើប្រាស់ទម្រង់មួយដែលសមស្របនឹងអ្នក។ គ្រូខ្លះត្រូវការការរំលឹកច្រើន។ ឯគ្រូខ្លះទៀត មានអារម្មណ៍ធុញថប់ជាមួយនឹងព័ត៌មានច្រើនពេក។ កម្រិតនៃព័ត៌មានលម្អិតដែលគួររួមបញ្ចូល ក៏អាស្រ័យលើប្រធានបទដែលត្រូវបង្រៀនផងដែរ។ ប្រសិនបើអ្នកចេះច្បាស់លើប្រធានបទដែលបង្រៀននោះ អ្នកប្រហែលជាត្រូវការតែលេខទំព័រនៃលំហាត់តែប៉ុណ្ណោះ។ ប្រសិនបើអ្នកមិនទាន់ចេះច្បាស់ទេអ្នកប្រហែលជាត្រូវការនិយមន័យជាច្រើនតារាងនិងការពន្យល់មួយចំនួននិងដំណោះស្រាយនៃលំហាត់ផងដែរ។



## គំរូទី១

ទម្រង់គំរូនេះ គឺជាទម្រង់ដែលត្រូវបានណែនាំឱ្យប្រើដោយវិទ្យាស្ថានជាតិអប់រំ (National Institute of Education) និងស្ថាប័នបណ្តុះបណ្តាលផ្សេងៗទៀត។ វាគឺជាទម្រង់ដែលត្រូវបានប្រើប្រាស់ច្រើនជាងគេនៅក្នុងប្រទេសកម្ពុជា។ ព្រោះតែលក្ខណៈស្តង់ដា ទើបវាអាចផ្តល់អត្ថប្រយោជន៍សម្រាប់ជាការពិភាក្សាជាមួយរដ្ឋបាលសាលា ឬជាមួយគ្រូបង្រៀនដែលត្រូវមកជំនួស។ ទោះជាយ៉ាងណាក៏ដោយ ចូរប្រាកដក្នុងចិត្តថាអត្ថប្រយោជន៍ទាំងនោះអាចយកឈ្នះលើគុណវិបត្តិ មុនពេលសម្រេចចិត្តប្រើប្រាស់វា។ ហានិភ័យនោះគឺការជាប់គាំងនៅក្នុងភាពមិនសមហេតុផលតាមបែបការិយាល័យធិបតេយ្យ (bureaucratic absurdity) ដែលយើងបានរិះគន់នៅដើមទំព័រនៃកូនសៀវភៅនេះ។

គំនិតនៅពីក្រោយនៃការប្រើគូឡោនទាំងបី (three columns) គឺដើម្បីបង្ខំឱ្យគ្រូគិតអំពីសកម្មភាពរបស់សិស្ស ដែលជាវិធីសាស្ត្រល្អ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងការអនុវត្ត គ្រូភាគច្រើនមានទំនោរធ្វើម្តងទៀតនូវគំនិតដដែលៗក្នុងគូឡោនទាំង៣។ វាមិនត្រឹមតែជាការខ្ជះខ្ជាយពេលវេលាប៉ុណ្ណោះទេប៉ុន្តែវាក៏ធ្វើឱ្យបាត់បង់នូវគោលបំណងគោលនៃទម្រង់គំរូនេះ ហើយ ធ្វើឱ្យវាមិនងាយស្រួលប្រើសម្រាប់គ្រូផងដែរ។

ជំហានទាំងប្រាំ (five steps) ក៏ត្រូវបានគេសន្មតថាជាការរំឮកពីកាតព្វកិច្ចសំខាន់ៗដល់គ្រូផងដែរ ជាពិសេសពេលវេលារំលឹកដើម្បីភ្ជាប់មេរៀនទៅនឹងមេរៀនមុន។ ទោះជាយ៉ាងណាក៏ដោយ រចនាសម្ព័ន្ធនោះបង្ហាញថាមានភាព

តឹងរ៉ឹងបន្តិច ហើយជួនកាលមិនពាក់ព័ន្ធទេ ជាពិសេសប្រសិនបើគ្រូបានរៀបចំសកម្មភាពយូរ និងមានន័យ ជាឧទាហរណ៍ ជាតុមួយនៃការសិក្សាតាមបែបគម្រោង (Project-Based Learning)។ ពេលវេលាបើក និងបិទមេរៀនមានទំនោរទៅជាសិប្បនិម្មិតបន្តិចបន្តួចនៅពេលខ្លះ។

## ចំណងជើងមេរៀន៖

______________________________________

- កម្រិតឬថ្នាក់៖ ______________________
- ជំពូកមេរៀន៖ ______________________
- មេរៀន ៖ ______________________
- ខ្លឹមសារមេរៀន៖ ______________________
- រយៈពេល ៖ ______________________
- ទំព័រ៖ ______________________

គោលបំណង៖ ______________________

វត្ថុបំណងមេរៀន៖ ______________________

សម្ភារៈឧបទ្ទេស៖______________________

| សកម្មភាពគ្រូ | ខ្លឹមសារ | សកម្មភាពសិស្ស |
| --- | --- | --- |
| រដ្ឋបាលថ្នាក់រៀន (កំណត់នាទី) | | |
| រំលឹកមេរៀនឡើងវិញ (កំណត់នាទី) | | |
| បង្រៀនមេរៀនថ្មី (កំណត់នាទី) | | |
| សកម្មភាពទី១ | | |
| សកម្មភាពទី២ | | |
| សកម្មភាពទី៣ | | |
| ការពង្រឹងពុទ្ធិ (កំណត់នាទី) | | |
| ការបិទមេរៀន/ កិច្ចការផ្ទះ(កំណត់នាទី) | | |

**យោបល់គ្រូ:**

## គំរូទី២

ទម្រង់គំរូនេះមិនធ្វើតាមវិធីសាស្ត្រជាក់លាក់ណាមួយនោះទេ។ វាសន្មតថាគ្រូបានដឹងរួចហើយថាតើជំហានណាខ្លះដែលមានសារៈសំខាន់នៅក្នុងការបង្រៀនមេរៀនមួយ។

ស្រដៀងគ្នានេះដែរ វត្ថុបំណងមេរៀនមិនធ្វើតាមរចនាសម្ព័ន្ធជាក់លាក់ណាមួយទេ (ដូចជា៖ វិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា) ហើយសន្មតថាគ្រូដឹងពីរបៀបសរសេរវត្ថុបំណងមេរៀនបានត្រឹមត្រូវ។ ទោះជាយ៉ាងណាក៏ដោយ ចំពោះឃ្លាជំរុញ "សិស្សអាច" គឺជាចំណុចចាប់ផ្តើមដ៏ល្អរួចទៅហើយ ដើម្បីតម្រង់ទិសការសម្រេចចិត្តរបស់គ្រូចំពោះអ្វីមួយដែលមានលក្ខណៈជាក់ស្តែង និងអាចសង្កេតបាន។

ការសង្កត់ធ្ងន់ទៅលើ "ការកំណត់" អាចបញ្ជាក់ថាមានលក្ខណៈជាក់ស្តែងក្នុងការកែសម្រួលសកម្មភាពដែលបានយកចេញពីសៀវភៅសិក្សា ឬប្រភពផ្សេងទៀត។ ជាទូទៅ វាជារឿងសំខាន់បំផុតដែលត្រូវសម្រេចចិត្តនៅពេលអ្នកបានជ្រើសរើសលំហាត់រួចរាល់។

"ចម្លើយដែលរំពឹងទុក" នឹងអាចជៀសវាងកំហុស ក្នុងករណីដែលគ្រូមិនសូវច្បាស់នឹងខ្លឹមសារនៃមេរៀន ហើយក៏ធានាថា ចំណុចសំខាន់ៗដែលត្រូវចងចាំមានភាពច្បាស់លាស់គ្រប់ពេលវេលា។

# រចនាសម្ព័ន្ធគំរូទី ២

ចំណងជើង

______________________________________________

- ថ្នាក់ ឬកម្រិត ________________________________
- កាលបរិច្ឆេទ __________________________________

វត្ថុបំណងមេរៀន ____________________________________

- សិស្សអាច ____________________________________

ចំណេះដឹងដែលចាំបាច់ ________________________________

- សិស្សបានដឹងរួចហើយ __________________________

សម្ភារៈ____________________________________________

- សម្ភារៈសម្រាប់សិស្ស _________________________
- សម្ភារៈសម្រាប់គ្រូ ___________________________

| សកម្មភាព | សម្ភារៈ ឬឯកសារយោង លេខទំព័រ | រយៈពេល | មតិយោបល់ |
|---|---|---|---|
| ជំហានទី ១៖ សំណួរ ឬសកម្មភាព | | | |
| ការកំណត់៖ ការងារបុគ្គល ការងារក្រុម ការពិភាក្សា ថ្នាក់ទាំងមូល ។ល។ | | | |
| ចម្លើយដែលរំពឹងទុក៖ | | | |
| ជំហានទី ២៖ សំណួរ ឬសកម្មភាព | | | |
| ការកំណត់៖ ការងារបុគ្គល ការងារក្រុម ការ | | | |

| សកម្មភាព | សម្ភារៈ ឬឯកសារយោង លេខទំព័រ | រយៈពេល | មតិយោបល់ |
|---|---|---|---|
| ពិភាក្សាថ្នាក់ទាំងមូល ។ល។ | | | |
| ចម្លើយដែលរំពឹងទុក | | | |
| ជំហានទី ៣៖ សំណួរ ឬសកម្មភាព | | | |
| ការកំណត់៖ ការងារបុគ្គល ការងារក្រុម ការពិភាក្សាថ្នាក់ទាំងមូល។ល។ | | | |
| ចម្លើយដែលរំពឹងទុក | | | |

| សកម្មភាព | សម្ភារៈ ឬឯកសារយោង លេខទំព័រ | រយៈពេល | មតិយោបល់ |
|---|---|---|---|
| ជំហានទី ៤៖ សំណួរ ឬសកម្មភាព | | | |
| ការកំណត់៖ ការងារបុគ្គល ការងារក្រុម ការពិភាក្សាថ្នាក់ទាំងមូល ។ល។ | | | |
| ចម្លើយដែលរំពឹងទុក | | | |

**គំរូទី ៣**

ទម្រង់គំរូនេះមានការរៀបចំជាជំហានមេរៀនបានយ៉ាងល្អ។ វាអាចមានភាពងាយស្រួលក្នុងការធានាថា ដំណើរការមានការគិតគូរបានម៉ត់ចត់។ ប៉ុន្តែគ្រូខ្លះអាចយល់ថា វាមានភាពតឹងរ៉ឹងពេក។

ការពិចារណាមួយចំនួន ដូចជាចំនួនសិស្សអាចបង្ហាញថាមានសារៈសំខាន់ នៅពេលដែលអ្នកត្រូវជ្រើសរើសវិធីសាស្ត្របង្រៀនដែលពាក់ព័ន្ធ ឬរៀបចំសន្លឹកកិច្ចការ និងសម្ភារៈបង្រៀនបានត្រឹមត្រូវ។

ភាពខុសគ្នារវាងគោលបំណង (aims) និងវត្ថុបំណងមេរៀន(objectives) អាចមានប្រយោជន៍ក្នុងការដាក់បញ្ចូលមេរៀនតាមទស្សនវិស័យ និងកំណត់អាទិភាពសកម្មភាព ប៉ុន្តែវាក៏អាចក្លាយមានភាពបត់បែន បន្តិចបន្តួចនៅពេលខ្លះ។



## ចំណាំជើង

ឈ្មោះគ្រូបង្រៀន៖ ថ្នាក់៖ ចំនួនសិស្សសរុប៖

កាលបរិច្ឆេទ៖ ពេលវេលា៖ សៀវភៅសិក្សាគោល៖

គោលបំណង៖

វត្ថុបំណងមេរៀន៖

ប្រភេទមេរៀន៖

រយៈពេល៖

ដំណើរការបង្រៀន៖

| ពេលវេលា | ជំហាន | ដំណើរការ ឬសកម្មភាព | វិធីសាស្ត្រ ឬសម្ភារៈបង្រៀន |
|---|---|---|---|
| | 1. បើកមេរៀន/រដ្ឋបាលថ្នាក់រៀន | | |
| | 2. រំលឹកមេរៀន | | |
| | 3. បង្រៀនមេរៀនថ្មី | | |
| | មុនធ្វើកិច្ចការ | | |

| | | | |
|---|---|---|---|
| | កិច្ចការបម្រុង | | |
| | ដំណាក់កាលអនុវត្ត | | |
| | បន្ទាប់ពីកិច្ចការ | | |
| | 4. បិទមេរៀន/កិច្ចការផ្ទះ | | |

**អក្សរកាត់៖ T= គ្រូបង្រៀន និង Ss. = សិស្ស**

## ឧបករណ៍ទី ៤៖ គំរូបញ្ញាសិប្បនិម្មិត សម្រាប់ការរៀបចំកិច្ចតែងការបង្រៀន

បញ្ជីឈ្មោះបញ្ញាសិប្បនិមិត្តទាំងនេះ ត្រូវបានរៀបចំឡើងនៅក្នុងខែមេសា ឆ្នាំ ២០២៥។ វាមិនមានការធានាថា ពួកវានៅតែល្អបំផុតនៅលើទីផ្សារ ឬថាពួកវានៅតែមាននោះទេ។ ចូរចាត់ទុកថាវាជាចំណុចចាប់ផ្តើមមុនពេលបង្កើតឧបករណ៍ផ្ទាល់ខ្លួនរបស់អ្នក។

### ១. ឧបករណ៍បង្កើតផែនការបង្រៀន (Lesson Plan Generators)

- MagicSchool AI (https://www.magicschool.AI/)
  - បង្កើតផែនការ/កិច្ចតែងការបង្រៀនដែលស្របតាមស្តង់ដាក្នុងរយៈពេលប៉ុន្មានវិនាទី (គាំទ្រ Common Core, NGSS, ។ល។)។
  - រួមបញ្ចូលយុទ្ធសាស្ត្របែងចែកសមត្ថភាពសិស្សនិងសកម្មភាពចូលរួម (differentiation strategies and engagement activities)។
- Education Copilot (https://app.educationcopilot.com/)
  - បង្កើតគំរូផែនការ/កិច្ចតែងការបង្រៀនជាង ១០+ (រួមទាំងស្លាយ សន្លឹកកិច្ចការ និងគំនិតគម្រោង)។
  - គាំទ្រផែនការ/កិច្ចតែងការបង្រៀនជាភាសាអេស្ប៉ាញ។

- AutoClassmate ( https://autoclassmate.io/ )
    - ផ្តោតលើការពិភាក្សាដោយប្រើ បញ្ញាសិប្បនិម្មិត និង UDL ( Universal Design for Learning - ការរចនាសកលសម្រាប់ការរៀនសូត្រ )។

**២. ឧបករណ៍បង្កើតខ្លឹមសារ និងធនធាន ( Content & Resource Generators )**

- Diffit ( https://web.diffit.me/ )
    - សម្របសម្រួលអត្ថបទ ឬវីដេអូណាមួយទៅជាអត្ថបទអានតាមកម្រិត ( ល្អសម្រាប់សិស្ស ELL/SPED )។
- Curipod ( https://curipod.com/ )
    - បង្កើតស្លាយអន្តរកម្មជាមួយនឹងការបោះឆ្នោត ពពកពាក្យ ( word clouds ) និងប្រធានបទពិភាក្សា។
- Canva Magic Write ( https://www.canva.com/magic-write/ )
    - ជួយរៀបចំសន្លឹកកិច្ចការ បទបង្ហាញ និងក្រាហ្វិកព័ត៌មាន ( infographics ) ដែលមើលទៅទាក់ទាញ។

- Synthesia: ( https://www.synthesia.io/ )
    - ឧបករណ៍បង្កើតវីដេអូ បញ្ញាសិប្បនិម្មិត ដែលអាចឱ្យអ្នកអប់រំបង្កើតខ្លឹមសារវីដេអូសម្រាប់មេរៀន ដែលធ្វើឱ្យដំណើរការរៀបចំផែនការកាន់តែមានភាពសកម្ម។

### ៣. ការស្រាវជ្រាវ និងការផ្ទៀងផ្ទាត់ការពិត ( Research & Fact-Checking )

- Elicit ( https://elicit.org/ )
    - ជំនួយការស្រាវជ្រាវ បញ្ញាសិប្បនិម្មិត ដែលសង្ខេបឯកសារសិក្សាសម្រាប់កិច្ចការស្រាវជ្រាវដែលពាក់ព័ន្ធនឹងមេរៀន។
- Perplexity AI ( https://www.perplexity.AI/ )
    - ផ្ដល់ចម្លើយដែលបានដកស្រង់និងទាន់សម័យសម្រាប់ប្រធានបទវិទ្យាសាស្ត្រ/ប្រវត្តិសាស្ត្រ ( ល្អជាង Google )។

### ៤. ការវាយតម្លៃ និងមតិកែលម្អ

- QuestionWell ( https://www.questionwell.org/ )

- បង្កើតកម្រងសំណួរដែលត្រូវបានដាក់ពិន្ទុដោយស្វ័យប្រវត្តិ (អាចនាំទៅរក Apps មួយចំនួន៖ Kahoot, Google Forms, ។ល។)។

- Brisk Teaching (Google Chrome extension)
  - ផ្តល់មតិកែលម្អតាមរយៈបញ្ញាសិប្បនិម្មិត លើអត្ថបទសិស្ស និងកែសម្រួលកម្រិតអាននៅក្នុង Google Docs។

## ៥. ការរៀនតាមតម្រូវការផ្ទាល់ខ្លួន និងការសម្របខ្លួន (Personalized & Adaptive Learning)

- Khanmigo (https://www.khanacademy.org/khan-labs)
  - បញ្ញាសិប្បនិម្មិតដែលដូចគ្រូបង្រៀនដែលជួយតម្រូវមេរៀនទៅតាមកម្រិតខុសៗគ្នារបស់សិស្សម្នាក់ៗ។

- Almanack AI (https://www.almanack.AI/)
  - បង្កើតសន្លឹកកិច្ចការ វីដេអូណែនាំ និងឧទ្ទេសបទសម្រាប់ដាក់ពិន្ទុ (grading rubrics) តាមតម្រូវការ។

ឧបករណ៍ទាំងនេះអាចពង្រឹងដំណើរការរៀបចំកិច្ចតែងការបង្រៀនរបស់អ្នក ធ្វើឱ្យវាមានរបៀប សហការគ្នា និងទាក់ទាញសម្រាប់សិស្ស។

- LessonPlan៖ ឧបករណ៍នេះផ្តល់នូវវេទិកាសហការសម្រាប់ការបង្កើត ការចែករំលែក និងការរៀបចំផែនការមេរៀន។ វារួមបញ្ចូលគំរូ និងធនធានជាច្រើនដែលត្រូវនឹងតម្រូវការអ្នកអប់រំ។ https://lessonplans.com/

- Kahoot! ៖ ទោះបីជាត្រូវបានគេស្គាល់ជាចម្បងសម្រាប់ការបង្កើតកម្រងសំណួរក៏ដោយ  ក៏Kahoot!បានផ្តល់នូវឧបករណ៍សម្រាប់បង្កើតផែនការមេរៀនអន្តរកម្មដែលអាចទាក់ទាញសិស្សតាមរបៀបសប្បាយរីករាយ។ https://kahoot.com/

- Socrative៖ ឧបករណ៍នេះអនុញ្ញាតឱ្យគ្រូបង្រៀនបង្កើតកម្រងសំណួរ និងសកម្មភាពអន្តរកម្មដែលស្របតាមផែនការមេរៀនរបស់ពួកគេ ធ្វើឱ្យវាងាយស្រួលក្នុងការវាយតម្លៃការយល់ដឹងរបស់សិស្ស។ https://socrative.com/

- Google Classroom៖ ជាឧបករណ៍ដ៏មានឥទ្ធិពលសម្រាប់គ្រប់គ្រងថ្នាក់រៀន និងធនធាន វាជួយក្នុងការរៀបចំផែនការមេរៀន និងចែករំលែកកិច្ចការជាមួយសិស្ស។ https://classroom.google.com/

- Teachmint៖ កម្មវិធីនេះផ្តល់នូវមុខងារសម្រាប់ការបង្កើតផែនការមេរៀនឌីជីថល ការធ្វើថ្នាក់រៀនផ្ទាល់ និងការគ្រប់គ្រងទិន្នន័យសិស្សប្រកបដោយប្រសិទ្ធភាព។ https://teachmint.com/

- Canva for Education៖ ទោះបីជាជាឧបករណ៍បែបប្រពៃណីសម្រាប់ការរចនាក៏ដោយ Canva ផ្តល់នូវគំរូជាក់លាក់សម្រាប់ការរៀបចំផែនការមេរៀន និងបទបង្ហាញអប់រំ។ https://www.canva.com/education

- Planbook៖ ជាអ្នករៀបចំកិច្ចតែងការបង្រៀនតាមអនឡាញដែលជួយអ្នកគ្រប់គ្រងផែនការមេរៀន ខណៈពេលដែលផ្តល់វិធីងាយស្រួលក្នុងការកែសម្រួល និងតម្រែតម្រង់ពួកវាជាមួយស្តង់ដា។ https://planbook.com/

ការរៀបចំផែនការមេរៀន(កិច្ចតែងការបង្រៀន)ជាញឹកញាប់ត្រូវបានគ្រូបង្រៀនចាត់ទុកថាជាកាតព្វកិច្ចរដ្ឋបាលដែលពួកគេធ្វើដើម្បីផ្គាប់ចិត្តនាយកសាលា និងអធិការអប់រំ។ ទោះបីជាជាទូទៅពួកគេទទួលស្គាល់ថាមេរៀនមានប្រសិទ្ធភាពជាងជាមួយនឹងយុទ្ធសាស្ត្រត្រឹមត្រូវក៏ដោយ ពួកគេនៅតែជួបការលំបាកក្នុងការសរសេរគំនិតរបស់ពួកគេដើម្បីបំពេញតាមតម្រូវការ ហើយចុងក្រោយទទួលបានត្រឹមតែឯកសារគ្មានន័យដែលគ្មាននរណាម្នាក់អាន។ សៀវភៅនេះពន្យល់ពីរបៀបរៀបកិច្ចតែងការបង្រៀនដើម្បីជាប្រយោជន៍ដល់សិស្ស និងគ្រូផ្ទាល់។ វាមានទម្រង់ផ្សេងៗគ្នាសម្រាប់ឱ្យគ្រូជ្រើសរើស និងរៀបចំផែនការមេរៀនទៅតាមតម្រូវការ និងស្ទីលបង្រៀនរបស់គាត់។

លោក Stanislas Kowalski គឺជាទីប្រឹក្សា (mentor) នៃ NGPRD ជាកន្លែងដែលគាត់គ្រប់គ្រង និងរៀបចំលើកម្មវិធីសិក្សា។ស្របពេលជាមួយគ្នានេះ គាត់ក៏បម្រើការជាទីប្រឹក្សាសម្រាប់កម្មវិធីផ្សេងៗរបស់ក្រសួងអប់រំ យុវជន និងកីឡា (MoEYS)។ គាត់ធ្លាប់ធ្វើការជាអ្នកអប់រំនៅក្នុងប្រទេសមួយចំនួន និងនៅកម្រិតថ្នាក់ផ្សេងៗគ្នា។នៅប្រទេសបារាំងគាត់គឺជាគ្រូបង្រៀនអក្សរសាស្ត្រនៅសាលាមធ្យមសិក្សា។ គាត់បានបង្រៀនភាសាបារាំងនៅសាកលវិទ្យាល័យ Central South ក្នុងទីក្រុង Changsha (ប្រទេសចិន) ហើយគាត់ក៏ជានាយកមជ្ឈមណ្ឌលអក្ខរកម្ម (alphabetization center) នៅក្នុងប្រទេស Djibouti ផងដែរ។

+855 11 607 938
ngprc@nie.edu.kh
facebook.com/ngprc16
https://ngprd.nie.edu.kh